# បំម្រែបម្រួល នៃឥទ្ធិពល

## មគ្គុទ្ទេសក៍យេនឌ័រសម្រាប់ស្ថាប័ន ដែលធ្វើការងារអំពីទំនប់និងទន្លេ



បឹងទូកាណា ពេលថ្ងៃរៀបលិច | រូបថតដោយ អង្គការទន្លេអន្តរជាតិ

INTERNATIONAL RIVERS
PEOPLE · WATER · LIFE

អ្នកនិពន្ធ៖  រ៉ូឌូ សានយ៉ានហ្គា, ម៉ៃឃើល សាយម៉ុន, និង គ្រីស្ទីណា ហ៊ីល

ក្រុមការងារត្រួតពិនិត្យ និងក្រុមការងារគាំទ្រនៃអង្គការទន្លេអន្តរជាតិ៖ អានហ្គី អាសានហ្ស៊ី, ស៊ីហ្ស៊ីវី ម៉ូតា, ម៉ាហ្គារ៉េត ចូវ និង តាហ្សាតវ៉ា ម៉ាហូបាបា។

រចនាទំព័រដោយ៖ សាលី វាញ

សៀវភៅមគ្គុទ្ទេសក៍នេះរៀបរៀងឡើងទៅបានដោយមានជំនួយសប្បុរសពីសម្ព័ន្ធសាកលដើម្បីសកម្មភាពបៃតង និងសមភាពយេនឌ័រ (the Global Alliance for Green Action and Gender Equality) តាមរយៈមូលនិធិជំនួយបៃតងសាកល (Global Green Grants Fund)។ ឧបត្ថម្ភថវិកាសម្រាប់ការបកប្រែភាសាដោយ ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងកិច្ចសហប្រតិបត្តិការ (Swiss Agency for Development and Cooperation–SDC)។

សៀវភៅមគ្គុទ្ទេសក៍នេះចងក្រងនូវបទពិសោធន៍ផ្ទាល់របស់អង្គការទន្លេអន្តរជាតិដែលបានធ្វើការជាមួយសហគមន៍ដែលនៅតាមដងទន្លេនៅជុំវិញពិភពលោក។ ជាពិសេស យើងបានសហការជាមួយដៃគូសង្គមស៊ីវិល តំណាងសហគមន៍ និងស្ត្រីជាច្រើននាក់ អំពីបទពិសោធន៍របស់ពួកគាត់ដែលរងផលប៉ះពាល់ដោយសារទំនប់អ៊ីនហ្គា (Inga) នៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ។ យើងសូមថ្លែងអំណរគុណដល់ សាឡូម អ៊ីឡូឡូ មកពីសម្ពន្ធស្ត្រីសាមគ្គី (Femmes Solidaires - FESO) និងប្លាឌីន អ៊ីឡានហ្គា បូនាហ្គា មកពីសម្ពន្ធស្ត្រីសាមគ្គីនៃដងទន្លេកុងហ្គោ (SOFFLECO) ខារ៉ូឡាញ តាវប៉ាន និង មេឡា ជីប៉ុនដា មកពីវ៉ូមីន (WoMin) និង ដូណា អានឌ្រូ ដែលបានប្រើប្រាស់សាកល្បងនិងផ្តល់មតិកែលម្អដល់មគ្គុទ្ទេសក៍នេះ។

យើងខ្ញុំសូមអញ្ជើញស្ថាប័ននិងបុគ្គលទាំងអស់ដែលបានប្រើប្រាស់មគ្គុទ្ទេសក៍នេះ ទាក់ទងទៅកាន់អង្គការទន្លេអន្តរជាតិ ដើម្បីផ្តល់ព័ត៌មានអំពីអត្ថប្រយោជន៍របស់វា មតិកែលម្អ ក៏ដូចជាយោបល់អំពីធនធានផ្សេងៗដែលអាចជួយគាំទ្រនិងកែលម្អការងារពាក់ព័ន្ធនឹងសិទ្ធិស្ត្រី ទំនប់ និងទន្លេ ឱ្យបានកាន់តែប្រសើរឡើង។

ប្រសិនបើមានចម្ងល់ឬយោបល់ផ្សេងៗ សូមទាក់ទង៖

ម៉ៃឃើល សាយម៉ុន (Michael Simon) តាមរយៈ msimon@internationalrivers.org

ស៊ីហ្ស៊ីវី ម៉ូតា (Siziwe Mota) តាមរយៈ smota@internationalrivers.org

ឬទាក់ទងទៅកាន់ contact@internationalrivers.org

បោះពុម្ពផ្សាយ ខែមីនា ឆ្នាំ២០២០។ រក្សាសិទ្ធិ ឆ្នាំ២០២០ ដោយអង្គការទន្លេអន្តរជាតិ។

**ការិយាល័យកណ្តាល អង្គការទន្លេអន្តរជាតិ**
1330 Broadway, ជាន់ទី៣
អូកលែន (Oakland), CA 94612, សហរដ្ឋអាមេរិក
ទូរសព្ទ៖ +1 510 848 1155
www.internationalrivers.org

**ការិយាល័យអាហ្វ្រិក អង្គការទន្លេអន្តរជាតិ**
អាគារការិយាល័យ F10, Pro-Equity Court
លេខ 1250 ផ្លូវព្រីតូរីស (Pretorius)
ហេតហ្វៀល (Hatfield), 0083
ព្រីតូរៀ (Pretoria) អាហ្វ្រិកខាងត្បូង
ទូរសព្ទ៖ +27 12 430 2029

# មាតិកា


**សេចក្តីផ្តើម** 2

**ផ្នែកទី១ ស្វែងយល់អំពីយេនឌ័រ** 4

១.១ ស្វែងយល់អំពីយេនឌ័រក្នុងបរិបទទំនប់ ទន្លេ និងសហគមន៍តាមដងទន្លេ 5

១.២ និយមន័យពាក្យគន្លឹះអំពីយេនឌ័រ 10

**ផ្នែកទី២ ការបញ្ជ្រាបយេនឌ័រនិងការវាយតម្លៃយេនឌ័រសម្រាប់ស្ថាប័ន** 12

**ផ្នែកទី៣ ការវិភាគយេនឌ័រ** 16

៣.១ តើការវិភាគយេនឌ័រគឺជាអ្វី 16

៣.២ ជំហានក្នុងការវិភាគយេនឌ័រ 19

**ជំហានទី១** ស្វែងយល់ថាស្ត្រីផ្តល់តម្លៃបែបណា ហើយបុរសផ្តល់តម្លៃបែបណាទៅឱ្យទន្លេ 20

**ជំហានទី២** ស្វែងយល់ពីការបែងចែកយេនឌ័រក្នុងកិច្ចការពលកម្ម 20

**ជំហានទី៣** ស្វែងយល់ថា តើនរណាមានសិទ្ធិប្រើប្រាស់ និងចាត់ចែងធនធានក្នុងគ្រួសារនិងសហគមន៍ 21

**ជំហានទី៤** ស្វែងយល់ពីឧបសគ្គនិងដំណោះស្រាយចំពោះការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត 21

**ជំហានទី៥** ស្វែងយល់ពីតម្រូវការយេនឌ័រជាក់ស្តែង និងផលប្រយោជន៍យេនឌ័រជាយុទ្ធសាស្ត្រសម្រាប់ស្ត្រី 21

**ជំហានទី៦** ស្វែងយល់ពីផលប៉ះពាល់នៃគម្រោងទំនប់ដែលបានស្នើ ដែលអាចកើតមានទៅលើស្ត្រីនិងបុរស 21

**ផ្នែកទី៤ ការរៀបចំនិងការអនុវត្តយុទ្ធនាការទំនប់និងទន្លេដែលឆ្លើយតបទៅនឹងយេនឌ័រ** 22

**ឯកសារឧបសម្ព័ន្ធ** 24

**ឧបសម្ព័ន្ធទី១** និយមន័យពាក្យគន្លឹះអំពីយេនឌ័រ 26

**ឧបសម្ព័ន្ធទី២** ការវាយតម្លៃយេនឌ័រសម្រាប់ស្ថាប័ន 28

**ឧបសម្ព័ន្ធទី៣** ការវាយតម្លៃយេនឌ័រសម្រាប់យុទ្ធនាការ 30

**ឧបសម្ព័ន្ធទី៤** ជំហានទី១ - ស្វែងយល់ថាស្ត្រីផ្តល់តម្លៃបែបណា ហើយបុរសផ្តល់តម្លៃបែបណាទៅឱ្យទន្លេ 32

**ឧបសម្ព័ន្ធទី៥** ជំហានទី២ - ស្វែងយល់ពីការបែងចែកយេនឌ័រក្នុងកិច្ចការពលកម្ម 34

**ឧបសម្ព័ន្ធទី៦** ជំហានទី៣ - ស្វែងយល់ថា តើនរណាមានសិទ្ធិប្រើប្រាស់ និងចាត់ចែងធនធានក្នុងគ្រួសារ និងសហគមន៍ 36

**ឧបសម្ព័ន្ធទី៧** ជំហានទី៤ - ស្វែងយល់ពីឧបសគ្គនិងដំណោះស្រាយ ចំពោះការចូលរួមរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចចិត្ត 38

**ឧបសម្ព័ន្ធទី៨** ជំហានទី៥ - ស្វែងយល់ពីតម្រូវការយេនឌ័រជាក់ស្តែង និងផលប្រយោជន៍យេនឌ័រ ជាយុទ្ធសាស្ត្រសម្រាប់ស្ត្រី 39

**ឧបសម្ព័ន្ធទី៩** ជំហានទី៦ - ស្វែងយល់ពីផលប៉ះពាល់នៃគម្រោងទំនប់ដែលបានស្នើ ដែលអាចកើតមាន ទៅលើស្ត្រីនិងបុរស 40

**ឧបសម្ព័ន្ធទី១០** បញ្ជីផ្ទៀងផ្ទាត់ផែនការយុទ្ធនាការដែលឆ្លើយតបទៅនឹងយេនឌ័រ 42

**ឯកសារយោង** 44

# សេចក្តីផ្តើម

**អង្គការទន្លេអន្តរជាតិ**គឺជាអង្គការមិនរកប្រាក់ចំណេញដែលធ្វើការដើម្បីការពារប្រព័ន្ធអេកូឡូស៊ីរបស់ទន្លេនិងសិទ្ធិរបស់សហគមន៍តាមដងទន្លេ។ យើងធ្វើការជាមួយប្រជាជនដែលរងផលប៉ះពាល់ដោយសារទំនប់ និងហេដ្ឋារចនាសម្ព័ន្ធទឹកនានា ហើយពួកគាត់រងគ្រោះដោយសារដំណើរការដែលមានលក្ខណៈកេងប្រវ័ញ្ច ដែលបណ្តាលឱ្យខូចបង់ធនធានធម្មជាតិនិងជីវភាពរបស់ពួកគាត់។ ពួកយើងសហការជាមួយដៃគូអង្គការសង្គមស៊ីវិលនានា នៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។

បទពិសោធន៍របស់អង្គការទន្លេអន្តរជាតិជាមួយសហគមន៍ដែលរងផលប៉ះពាល់ដោយសារទំនប់បានបង្ហាញឱ្យឃើញម្តងហើយម្តងទៀតថា ទំនប់បង្កផលប៉ះពាល់ដល់សហគមន៍ក្នុងកម្រិតខុសគ្នាទៅតាមយេនឌ័រ។ គម្រោងទំនប់ខ្នាតធំដែលបង្កផលប៉ះពាល់ដូចជា ការបង្ខំឱ្យមានការផ្លាស់ទីលំនៅ ការជន់លិចដីធ្លី និងបម្លាស់ប្តូរប្រព័ន្ធទឹកទន្លេដែលបង្កជាទឹកជំនន់ឬជាគ្រោះរាំងស្ងួត នៅតាមតំបន់ព្រៃលិចទឹកនិងទំនាបលិចទឹក ជាដើម បានបង្កផលប៉ះពាល់ទៅលើស្ត្រីនិងបុរសក្នុងកម្រិតខុសគ្នា ។

ហេតុដូច្នេះហើយ ទើបអង្គការទន្លេអន្តរជាតិជំរុញឱ្យអ្នកគាំទ្រលើការកសាងទំនប់ធ្វើការវាយតម្លៃទៅលើផលប៉ះពាល់ដោយផ្សារភ្ជាប់នឹងយេនឌ័រ ដើម្បីស្វែងយល់ពីផលប៉ះពាល់ទៅលើស្ត្រីនិងបុរសក្នុងរូបភាពខុសៗគ្នា អាស្រ័យទៅតាមលក្ខណៈរបស់ទន្លេ គម្រោងទំនប់ និងសហគមន៍ដែលរងផលប៉ះពាល់។ នៅក្នុងការវាយតម្លៃទៅលើលទ្ធភាពកសាងទំនប់ និងជម្រើសនានាសម្រាប់ទំនប់ ក៏ដូចជាដំណើរការវាយតម្លៃផលប៉ះពាល់ ចាំបាច់ត្រូវមានការចូលរួមពីស្ត្រីផងនិងបុរសផង ពីព្រោះពួកគាត់គឺជាតំណាងឱ្យក្រុមដែលមានចំណាប់អារម្មណ៍ខុសគ្នា។ ការយល់ដឹងអំពីផលប៉ះពាល់របស់ទំនប់ទៅលើស្ត្រីនិងបុរសអាចជួយឱ្យយើងរិះរកវិធីបញ្ចៀសឬកាត់បន្ថយផលប៉ះពាល់ ឬកំណត់បាននូវវិធីក្នុងការផ្តល់សំណងដែលភាគីអ្នកកសាងទំនប់អាចផ្តល់ឱ្យ ដោយគោរពលើសិទ្ធិស្ត្រីនិងបុរស ក៏ដូចជាបានឆ្លើយតបទៅនឹងផលប្រយោជន៍និងតម្រូវការពួកគាត់។

## ភេទ យេនឌ័រ និងបរិយាប័ន្ន

សៀវភៅនេះប្រើភាសាអំពី"យេនឌ័រ" ពីព្រោះវាផ្តោតលើទំនាក់ទំនងសង្គមនិងឥទ្ធិពលរបស់ភាគីពាក់ព័ន្ធ នៅក្នុងបរិបទយេនឌ័រ។ យើងសម្គាល់ឃើញថាគម្រោងទំនប់មានផលប៉ះពាល់ទៅលើទាំងបុរសនិងស្ត្រី (រួមទាំងកុមារា និងកុមារី) ដោយមិនអាចត្រឡប់ទៅរកភាពល្អដូចដើមឡើយ។ នៅក្នុងមគ្គុទ្ទេសក៍នេះ យើងផ្តោតសំខាន់ទៅលើស្ត្រី ពីព្រោះស្ត្រីរងផលប៉ះពាល់អវិជ្ជមានក្នុងកម្រិតមិនសមាមាត្រគ្នា ហើយភាគច្រើន កាលណាគេនិយាយដល់ទំនប់និងការសម្រេចចិត្តទៅលើធនធានទឹក គេមិនសូវបានយកចិត្តទុកដាក់លើទស្សនៈនិងជីវិតរបស់ស្ត្រីឡើយ។

ថ្វីបើយើងផ្តោតទៅលើស្ត្រី យើងក៏មើលឃើញផងដែរថា មានការរើសអើងនិងវិសមភាពកើតឡើងចំពោះក្រុមប្រជាជនដទៃទៀតនៅក្នុងសហគមន៍ ជាពិសេស ជនជាតិភាគតិច សាសនាភាគតិច និងជនជាតិដើមភាគតិច។ បញ្ហាបាត់បង់ឱកាសនិងសិទ្ធិអំណាចគឺជាតថភាពពិតដែលកើតមានចំពោះមនុស្សជាច្រើន គ្រប់យេនឌ័រ និងគ្រប់ភេទ។ លក្ខណៈវប្បធម៌សង្គមបង្កើតឱ្យមានយេនឌ័រ ហើយយើងទទួលស្គាល់ថា អាចមានយេនឌ័រច្រើនដោយមិនកំណត់ត្រឹមតែលក្ខណៈទ្វេរវាងបុរសនិងស្ត្រីប៉ុណ្ណោះទេ។ ក្នុងបរិបទខ្លះ យេនឌ័រអាច បែងចែកទៅតាមក្រុម (LGBTQIA) ដូចជា ស្រីស្រលាញ់ស្រី ប្រុសស្រលាញ់ប្រុស អ្នកស្រឡាញ់ទាំងស្រីទាំងប្រុស អ្នកកែភេទ អ្នកមានចំណូលភេទចម្រុះ អ្នកមានសរីរាង្គភេទមិនប្រុសមិនស្រីពីកំណើត និងអ្នកដែលគ្មានចំណូលផ្លូវភេទ។ ប៉ុន្តែនៅក្នុងបរិបទខ្លះទៀត គេមិនកំណត់យេនឌ័រទៅតាមក្រុមទេ តែគេចាត់ទុកថាយេនឌ័រមានលក្ខណៈចម្រុះឬបត់បែន។ ការគិតដូច្នេះ អាចជួយឱ្យយើងយល់ដឹងបានត្រឹមត្រូវជាងការកំណត់យេនឌ័រទៅតាមក្រុម។ **ក្រុមភេទភាគតិចនិងយេនឌ័រភាគតិច**ទទួលរងនូវភាពអយុត្តិធម៌ចម្រុះគ្រប់ទម្រង់ ដោយសារការបាត់បង់ឱកាស ការរើសអើង និងកង្វះឥទ្ធិពលនិងភាពជាស្ថាប័ន។

អ្នកអាចយកឧបករណ៍នៅក្នុងសៀវភៅមគ្គុទេសក៍នេះទៅកែសម្រួល និងបំពេញបន្ថែមដើម្បីរួមបញ្ចូលនូវទម្រង់យេនឌ័រផ្សេងៗ។ នៅក្នុងការសម្ភាសន៍ឬការពិភាក្សាក្រុម ចាំបាច់ត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការសម្របសម្រួល និងការពារអត្តសញ្ញាណយេនឌ័រផ្ទាល់ខ្លួន និងពិចារណាអំពីការរើសអើងដែលអាចកើតមាន។

ជាកិច្ចចាំបាច់ដូចគ្នាដែរ អង្គការសង្គមស៊ីវិលនិងអង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រដល់សហគមន៍រងគ្រោះដោយសារទំនប់ ត្រូវគិតគូរទៅលើផលប៉ះពាល់ តម្រូវការ និងផលប្រយោជន៍ផ្សេងគ្នារវាងស្ត្រី និងបុរស។

អង្គការទន្លេអន្តរជាតិលើកទឹកចិត្តឱ្យស្ថាប័នដែលតស៊ូមតិលើទំនប់និងដើម្បីទន្លេ និងដែលធ្វើការជាមួយសហគមន៍រងគ្រោះដោយសារទំនប់ អនុវត្តការងារដោយឆ្លើយតបទៅនឹងយេនឌ័រ និងសហការជាមួយស្ត្រី និងអង្គការស្ត្រី ក្នុងគោលបំណងលើកកម្ពស់ផលប្រយោជន៍របស់ស្ត្រីនិងបុរស។

សៀវភៅមគ្គុទ្ទេសក៍នេះផ្តោតលើការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងសហគមន៍រងគ្រោះដោយសារការអភិវឌ្ឍទំនប់ ប៉ុន្តែយើងក៏ទទួលស្គាល់និងមិនមើលរំលងបុគ្គលដែលមិនអនុលោមតាមតួនាទីទ្វេយេនឌ័រនោះទេ។ ទស្សនៈរបស់យើងស្តីអំពីស្ត្រីនិងបុរសនៅក្នុងមគ្គុទេសក៍នេះមានមូលដ្ឋានលើក្របខ័ណ្ឌទ្វេយេនឌ័រ ដែលបានចាក់ឫសនៅក្នុងសហគមន៍ជាច្រើន។ យើងទទួលស្គាល់ថា ទស្សនៈនេះអាចនឹងបង្កហានិភ័យដោយបង្កើនការមើលរំលងនិងការរើសអើងចំពោះបុគ្គលដែលមិនអនុលោមតាមក្របខ័ណ្ឌទ្វេយេនឌ័រ។ ប៉ុន្តែចេតនារបស់យើងគឺចែករំលែកនូវធនធាននិងមេរៀនជាប្រយោជន៍ ដើម្បីយល់ដឹងអំពីផលប៉ះពាល់នៃការអភិវឌ្ឍទំនប់ទៅលើយេនឌ័រ និងផ្តល់នូវឧបករណ៍នានាដែលអ្នកអាចយកទៅកែសម្រួលនិងប្រើប្រាស់ក្នុងក្របខណ្ឌមួយដែលទូលំទូលាយជាងទស្សនៈទ្វេយេនឌ័រ ប្រុស-ស្រីទៅទៀត។

មគ្គុទ្ទេសក៍នេះមានគោលបំណងជួយដល់អង្គការសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាលនិងក្រុមសហគមន៍ ក្នុងការកែលម្អនិងលើកកម្ពស់ការអនុវត្តយេនឌ័រផងដែរ។ ជាពិសេស មគ្គុទ្ទេសក៍នេះផ្តល់នូវធនធានសម្រាប់ស្ថាប័នដែលគាំទ្រសហគមន៍រងគ្រោះដោយសារហេដ្ឋារចនាសម្ព័ន្ធទំនប់ខ្នាតធំ។ យើងបានរៀបចំសៀវភៅនេះក្នុងបំណងបង្កភាពងាយស្រួល សម្រាប់អ្នកដែលពុំមានជំនាញផ្នែកយេនឌ័រ ដើម្បីវាយតម្លៃនិងកែលម្អការងារពួកគាត់។ សំណួរដែលត្រូវចោទសួរគឺ៖ តើយើងអាចរួមបញ្ចូលយេនឌ័រទៅក្នុងការងារបានដោយរបៀបណា? ក្នុងបរិបទនៃការអភិវឌ្ឍទំនប់ តើយើងអាចរួមចំណែកលើកកម្ពស់ផលប្រយោជន៍និងសិទ្ធិស្ត្រី ក៏ដូចជាបុរស បានដោយរបៀបណា?

សៀវភៅមគ្គុទ្ទេសក៍នេះចែកចេញជាបួនផ្នែក រួមជាមួយនឹងឧបសម្ព័ន្ធមួយផ្នែកដែលមាននូវឧបករណ៍និងធនធានជំនួយ។

**ផ្នែកទី១៖**
ព័ត៌មានអំពីផលប៉ះពាល់យេនឌ័រដោយសារទំនប់ និងនិយមន័យពាក្យគន្លឹះអំពីយេនឌ័រ

**ផ្នែកទី២៖**
សេចក្តីណែនាំនិងឧបករណ៍ជំនួយដល់ស្ថាប័នដើម្បីពិនិត្យនិងឆ្លុះបញ្ចាំងអំពីការអនុវត្តយេនឌ័ររបស់ស្ថាប័ន និងនៅក្នុងយុទ្ធនាការដែលខ្លួនកំពុងអនុវត្ត

**ផ្នែកទី៣៖**
សេចក្តីណែនាំនិងឧបករណ៍ជំនួយដល់ស្ថាប័នដើម្បីវិភាគអំពីយេនឌ័រនិងសិក្សាមើលថា តើគម្រោងទំនប់អាចប៉ះពាល់ស្ត្រីយ៉ាងណាខ្លះ និងបុរសយ៉ាងណាខ្លះ

**ផ្នែកទី៤៖**
សេចក្តីណែនាំសម្រាប់ស្ថាប័ននិងសម្ព័ន្ធ ដើម្បីធានាថាយុទ្ធនាការរបស់ខ្លួនផ្តោតការយកចិត្តទុកដាក់ខ្លាំងលើយេនឌ័រ

**ឧបសម្ព័ន្ធ៖**
ឧបករណ៍ ទម្រង់គំរូ និងធនធានសម្រាប់វិភាគយេនឌ័រ

សៀវភៅមគ្គុទេសនេះមានបង្ហាញពីករណីសិក្សា បញ្ជីផ្ទៀងផ្ទាត់ ទម្រង់គំរូ និងឧបករណ៍វិភាគនិងធ្វើផែនការដែលមាននៅក្នុងឧបសម្ព័ន្ធនៃសៀវភៅនេះ និងអាចទាញយកបានពី www.internationalrivers.org/transforming-power

## ផ្នែកទី១

# ស្វែងយល់អំពីយេនឌ័រ



ក្រុមអ្នកថែរក្សាទឹកនៅឆ្មេរបានី - ប្រទេសសេនីហ្គាល់ អបអរទិវាទឹកទន្លេ ឆ្នាំ២០១៥។ នៅក្នុងការប្រមូលផ្តុំមួយ ក្រុមអ្នកថែរក្សាទឹកបានប្រមូលផ្តុំគ្នានិងបង្ហាញរូបភាព ដើម្បីរំឮកដល់ បេតា កាសីរេស ដែលជាអ្នកការពារទន្លេដ៏ល្បីល្បាញពីប្រទេសហុងឌូរ៉ាស ដែលត្រូវបានគេធ្វើឃាត ដោយសារគាត់ការតស៊ូប្រឆាំងនឹងគម្រោងទំនប់ដែលបំផ្លិចបំផ្លាញសហគមន៍គាត់។ | រូបថតដោយ ក្រុមអ្នកថែរក្សាទឹកនៅឆ្មេរបានី។

# ១.១ ស្វែងយល់អំពីយេនឌ័រក្នុងបរិបទទំនប់ទន្លេ និងសហគមន៍តាមដងទន្លេ

> ដោយសារគេមិនបានបញ្ចូលយេនឌ័រ ទៅក្នុងដំណាក់កាលរៀបចំផែនការ គម្រោងទំនប់ធំៗភាគច្រើនបានបង្កឱ្យ មានអតុល្យភាពក្នុងទំនាក់ទំនងយេនឌ័រ កាន់តែធ្ងន់ធ្ងរឡើង។ នៅក្នុងចំណោម សហគមន៍រងគ្រោះ ទំនប់បានបង្កើននូវ វិសមភាពយេនឌ័រ ដោយបង្កើនបន្ទុក ចំពោះស្ត្រីក្នុងកម្រិតមិនសមាមាត្រ ឬ បែងចែកអត្ថប្រយោជន៍មិនស្មើភាពគ្នា។”

*ទំនប់និងការអភិវឌ្ឍ៖ ក្របខ័ណ្ឌថ្មីសម្រាប់ធ្វើសេចក្ដីសម្រេចចិត្ត*
របាយការណ៍របស់គណៈកម្មការទំនប់ពិភពលោក។

ទន្លេនិងធនធានទន្លេគឺជាផ្នែកដ៏សំខាន់នៃប្រព័ន្ធអេកូឡូស៊ីពិភពលោករបស់យើង ដែលទ្រទ្រង់ជីវភាព ប្រព័ន្ធស្បៀង និងសេដ្ឋកិច្ចរបស់យើង។ ទន្លេ ស្ទឹង បឹងទឹកសាប និងដៃរបស់វាគឺជាទីជម្រកជីវចម្រុះដ៏សំខាន់ ដែលច្រើនតែមិនសូវបានសិក្សាស៊ីជម្រៅ និងរងការគំរាមកំហែង ការបំពាន និងការប្រើប្រាស់ហួសកម្រិត ដោយសារកង្វះការអភិរក្សនិងកង្វះការរក្សាឱ្យបាននូវបរិស្ថានធម្មជាតិរបស់ប្រព័ន្ធអេកូឡូស៊ីទឹកសាប។

អ្នកប្រើប្រាស់ផ្សេងគ្នាផ្ដល់តម្លៃខុសគ្នាទៅលើទន្លេ ទឹកទន្លេ និងធនធាននានាក្នុងអាងទន្លេ ដែលច្រើនតែបណ្ដាលឱ្យមានការខ្វែងគំនិតគ្នាអំពីទន្លេនិងការប្រើប្រាស់ទឹកទន្លេ។ ជាទូទៅ ភាគីអ្នកប្រើប្រាស់ខ្លះ (អ្នកអភិវឌ្ឍទំនប់ឬប្រព័ន្ធធារាសាស្ត្រ) បង្កការខូចខាតដល់ផលប្រយោជន៍របស់ភាគីអ្នកប្រើប្រាស់ដទៃទៀត (ដូចជាសហគមន៍តាមដងទន្លេ)។ ការសាងសង់ទំនប់និងទាញយកទឹកសម្រាប់កសិកម្មខ្នាតធំ ឬខ្នាតឧស្សាហកម្ម ភាគច្រើនជះឥទ្ធិពលដល់លទ្ធភាពរស់រាននិងភាពចម្រុះនៃប្រព័ន្ធធម្មជាតិ។ ការតភ្ជាប់រវាងទន្លេទៅកាន់ទីជម្រាលនៅតំបន់ខ្ពង់រាប តំបន់ទំនាបលិចទឹក ដីព្រៃលិចទឹក និងទីជម្រកនានាតាមវាលទំនាប គឺជាគន្លឹះដ៏សំខាន់សម្រាប់រក្សាសុខភាពប្រព័ន្ធអេកូឡូស៊ីទឹកសាប ជីវចម្រុះ និងជីវភាពរបស់ប្រជាជនរាប់លាននាក់នៅជុំវិញពិភពលោក។

ទន្លេគឺជាជីវិតរបស់សហគមន៍តាមដងទន្លេ។ ទឹកផ្តល់នូវស្បៀងអាហារ ហើយទឹកគឺជាធនធានចាំបាច់បំផុតសម្រាប់មនុស្ស និងជាប្រភពទឹកសម្រាប់បរិភោគ ងូត លាងសម្អាត និងធ្វើកសិកម្ម។ វាផ្តល់លទ្ធភាពដល់សហគមន៍តាមដងទន្លេក្នុងការនេសាទ ប្រមូលផលរុក្ខជាតិនិងសត្វក្នុងទឹក ប្រើទឹកសម្រាប់ចិញ្ចឹមសត្វ និងស្រោចស្រពដំណាំឬចំការ។ ទន្លេក៏មានតួនាទីជាមជ្ឈមណ្ឌលដឹកជញ្ជូនមួយ ដែលតភ្ជាប់រវាងមនុស្សនិងមនុស្ស និងសម្រាប់ដឹកជញ្ជូនទំនិញឬផ្តល់សេវាកម្មនានា។ នៅក្នុងបរិបទវប្បធម៌និងជំនឿរបស់ប្រជាជនមួយចំនួន គេគោរពបូជាចំពោះទន្លេ ពីព្រោះទន្លេបានអនុញ្ញាតិឱ្យមនុស្សឈរជើងបាននៅទីកន្លែងមួយដែលផ្សារភ្ជាប់ទៅនឹងប្រវត្តិសាស្រ្ត ទេវកថា និងរឿងរ៉ាវនានា។

ជនជាតិដើមភាគតិចជាច្រើនយកចិត្តទុកដាក់និងគោរពទៅលើទំនាក់ទំនងរវាងប្រជាជនរបស់ពួកគាត់ ជាមួយនឹងទឹកនិងដីរបស់ពួកគាត់។ នៅពេលដែលយើងយល់អំពីមូលហេតុដែលមនុស្សផ្តល់តម្លៃទៅលើទន្លេ យើងនឹងកាន់តែងាយយល់អំពីកម្លាំងជំរុញនិងភាពតានតឹងពាក់ព័ន្ធនឹងការចាត់ចែងធនធាននេះ។ ដើម្បីធ្វើកិច្ចការនេះបាន ចាំបាច់យើងត្រូវយល់អំពីយេនឌ័រនៅក្នុងការគ្រប់គ្រងនិងប្រើប្រាស់ធនធានទឹក។ មានកិច្ចការមួយចំនួនគឺជាការទទួលខុសត្រូវរួមគ្នារវាងបុរសនិងស្រ្តី ប៉ុន្តែនៅក្នុងទិដ្ឋភាពនៃការប្រើប្រាស់ទឹកនៅសហគមន៍ គេចាត់ទុកថាកិច្ចការនិងទំនួលខុសត្រូវភាគច្រើនជារបស់ស្រ្តី។

ជាទូទៅ ស្រ្តីនិងបុរសមាននាទីផ្សេងគ្នាក្នុងការចាត់ចែងនិងថែទាំទឹក ហើយតួនាទីខ្លះត្រូវបានកំណត់នៅក្នុងជំនឿឬជាច្បាប់ទម្លាប់។ នៅក្នុងវប្បធម៌និងសង្គមជាច្រើន ស្រ្តីនិងក្មេងស្រីគឺជាអ្នកដែលមានភារកិច្ចទៅរកទឹក និងចាត់ចែងទឹកនៅក្នុងគ្រួសារ។ ស្រ្តីដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ ចាត់ចែង និងការការពារធនធានទឹក ប៉ុន្តែការចូលរួមរបស់ស្រ្តីក្នុងការសម្រេចចិត្តលើធនធានទឹកនៅតែមានកម្រិត ឬខ្វះការទទួលស្គាល់។ ជារឿយៗ គេច្រើនមើលរំលង និងមិនឱ្យតម្លៃលើការទទួលខុសត្រូវនិងភាពជាអ្នកដឹកនាំរបស់ស្រ្តីឡើយ។

ប្រជាជនដែលរងគ្រោះបំផុតដោយសារទំនប់និងគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗ ភាគច្រើនគឺជាក្រុមបាត់បង់ឱកាសនៅក្នុងសហគមន៍ ដែលភាគច្រើនពឹងផ្អែកលើធនធានធម្មជាតិ ដី និងទន្លេ ដើម្បីជីវភាពរស់នៅនិងសុខុមាលភាពផ្នែកសេដ្ឋកិច្ច។

ជាឧទាហរណ៍ នៅទូទាំងទ្វីបអាហ្វ្រិក បទពិសោធន៍កន្លងមកបង្ហាញថា ក្រុមប្រជាជនដែលបាត់បង់ឱកាសទាំងនេះភាគច្រើនខ្វះការទទួលបានការអប់រំនិងសេវាសាធារណៈនានា។ ប្រជាជនរងគ្រោះដោយសារទំនប់ ឬងាយរងគ្រោះដោយសារគម្រោងទំនប់ដែលកំពុងស្នើសាងសង់ ភាគច្រើនមិនត្រូវបានរួមបញ្ចូលក្នុងការសម្រេចចិត្ត ហើយទទួលរងនូវការរំលោភសិទ្ធិចម្រុះ។ ក្នុងករណីភាគច្រើន ស្រ្តីមកពីសហគមន៍រងគ្រោះដោយសារទំនប់ គឺជាអ្នកដែលទទួលនូវផលប៉ះពាល់អវិជ្ជមានពីការអភិវឌ្ឍទំនប់ ក្នុងកម្រិតដែលមិនសមាមាត្រ។

> “ស្ទើរគ្រប់ពេល បុរសគឺជាអ្នករៀបចំផែនការផ្លាស់ប្តូរទីលំនៅ ដោយគិតគូរពីបុរសជាចម្បង។ ជាលទ្ធផល បុរសក្លាយជាអ្នកកាន់កាប់កម្មសិទ្ធិដីធ្លីនិងទ្រព្យសំណងថ្មី ដោយមិនគិតពីកម្មសិទ្ធិដីធ្លីដើម មុនពេលផ្លាស់ទី។
>
> ទន្ទឹមនឹងនេះ គម្រោងកម្រគិតគូរអំពីឱកាសរបស់ស្រ្តីក្នុងការរកប្រាក់ចំណូលណាស់ ហើយការងាររបស់ស្រ្តីភាគច្រើនត្រូវបានកំណត់ឱ្យនៅត្រឹមតែកិច្ចការជុំវិញផ្ទះដែលគ្មានចំណូល...
>
> ជាលទ្ធផល ស្រ្តីបាត់បង់ជំហជាសមាជិកបង្កើនផលិតភាពនិងភាពជាដៃគូក្នុងការសម្រេចចិត្តនៅក្នុងគ្រួសារ ដែលបណ្តាលឱ្យបាត់បង់ឋានៈសង្គមនិងសេដ្ឋកិច្ច។”

អេលីសាបែត ខូលសាន់ និងថាយើ ស្គូឌ័រ, *សុខុមាលនិងការអភិវឌ្ឍ៖ ក្របខ័ណ្ឌគំនិតសម្រាប់ការវិភាគអំពីប្រជាជនដែលត្រូវផ្លាស់ប្តូរទីលំនៅ។*

គម្រោងទំនប់នឹងបង្កើនអតុល្យភាពសិទ្ធិអំណាចរវាងស្ត្រីនិងបុរស ដោយស្ត្រីគឺជាអ្នកទទួលនូវភាពរងគ្រោះច្រើន ចំណែកបុរសគឺជាអ្នកទទួលបានប្រយោជន៍ភាគច្រើន ក្នុងចំណែកដែលមិនសមាមាត្រគ្នា។

**ផលប៉ះពាល់ដែលច្រើនតែកើតមានចំពោះស្ត្រីនៅតាមសហគមន៍រងគ្រោះ ក្នុងអំឡុងពេលអភិវឌ្ឍ និងដំណើរការគម្រោងទំនប់មានដូចជា៖**

### ក្រុមគ្រួសារ

- អំពើហិង្សាក្នុងគ្រួសារ
- ការបំពានដោយហិង្សា និងអំពើប្លន់
- ការងារលំបាក
- ការបាត់បង់លទ្ធភាពទទួលបានធនធានធម្មជាតិ សម្រាប់ម្ហូបអាហារនិងប្រាក់ចំណូល
- ជំងឺកាមរោគនិងការរីករាលដាលនៃមេរោគនិងជំងឺអេដស៍
- អសន្តិសុខស្បៀង

### ដីនិងធនធាន

- បញ្ហានៅក្នុងការរៀបចំដីបម្រុង និងសំណងដីធ្លី
- ការបាត់បង់ជីវភាព និងមុខរបររកចំណូល
- ការបាត់បង់ដើមទុនសង្គម នៅពេលផ្លាស់ទីលំនៅ
- បាត់បង់កម្មសិទ្ធិដីធ្លីពីប្រពៃណីដូនតា
- ខ្វះការទទួលបាន ខ្វះភាពជាម្ចាស់ និងខ្វះលទ្ធភាពគ្រប់គ្រងធនធានដែលពួកគាត់ពឹងផ្អែកលើ

### សេវាកម្មនិងស្ថាប័ន

- ខ្វះលទ្ធភាពទទួលបានឬទទួលបានតិចតួចនូវសេវាសុខភាពនិងការអប់រំ
- ការផ្តល់សំណងមិនគ្រប់គ្រាន់សម្រាប់ទ្រព្យសម្បត្តិដែលបាត់បង់
- កង្វះលទ្ធភាពទទួលបានប្រព័ន្ធយុត្តិធម៌និងជំនួយពីអ្នកធ្វើសេចក្តីសម្រេចចិត្ត

### ព័ត៌មាននិងដំណោះស្រាយ

- កង្វះព័ត៌មានអំពីជម្រើសនិងមធ្យោបាយដោះស្រាយបញ្ហារបស់ពួកគាត់
- កង្វះព័ត៌មានអំពីសិទ្ធិរបស់ពួកគាត់
- យន្តការបណ្តឹងតវ៉ាខ្សោយ ឬគ្មានយន្តការតែម្តង

ទំនប់និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធអាចជាបុព្វហេតុនៃផលប៉ះពាល់អវិជ្ជមាន ដូចជា ទឹកជន់លិចផលដំណាំនិងស្រែចំការ និងការបាត់បង់ដីធ្លីសម្រាប់ប្រើប្រាស់ទៅតាមទំនៀមទម្លាប់។ ផលប៉ះពាល់ដែលតែងកើតមានជាទូទៅគឺការផ្លាស់ទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត ដោយពួកគាត់ត្រូវបានបង្ខំឱ្យចាកចេញពីដីធ្លីឬផ្ទះ ដើម្បីគេសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ឬដើម្បីរក្សាទុកដីនោះជាអាងស្តុកទឹក។ ទាំងនេះគឺជាបទពិសោធន៍របស់សហគមន៍អ៊ីនហ្គា នៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គូ (សូមមើលករណីសិក្សានៅទំព័របន្ទាប់)។

ផលប៉ះពាល់អវិជ្ជមាននិងផលប៉ះពាល់យេនឌ័រក៏កើតមានឡើងផងដែរ នៅក្នុងដំណើរការពិគ្រោះយោបល់និងកិច្ចប្រជុំដែលរៀបចំឡើងដោយរដ្ឋាភិបាលឬក្រុមហ៊ុន។ នៅពេលប្រាស្រ័យទាក់ទងជាមួយអាជ្ញាធរឬអ្នកមកពីក្រៅ ទម្លាប់សង្គមច្រើនតែចាត់ទុកថាបុរសគឺជាជនបង្គោលក្នុងការទំនាក់ទំនងឬការសម្រេចចិត្តសម្រាប់ក្រុមគ្រួសារនិងសហគមន៍។ នៅក្នុងបរិបទនេះ ភាគច្រើនបុរសគឺជាអ្នកចាត់ចែងលើការពិគ្រោះយោបល់ អំពីសំណើរសាងសង់ទំនប់ ផលប៉ះពាល់របស់ទំនប់និងនីតិវិធីផ្តល់ដំណោះស្រាយនិងសំណង។ ប្រសិនបើពុំមានការប្តេជ្ញា និងចេតនាឱ្យស្ត្រីចូលរួមនៅក្នុងការសម្រេចចិត្តទេ ទម្លាប់បែបនេះនឹងនៅតែបន្តឱ្យបុរសជាអ្នកសម្រេចជំនួសឱ្យក្រុមគ្រួសាររងគ្រោះ។ ជាលទ្ធផល គេនឹងនៅតែបន្តព្រងើយកន្តើយចំពោះតម្រូវការនិងផលប្រយោជន៍របស់ស្ត្រី។



ជំរំគីនសាសា កុងហ្គូកណ្ដាល, កិច្ចប្រជុំប្រឹក្សាជាមួយស្ត្រី | រូបថតដោយ អង្គការទន្លេអន្តរជាតិ២០១៧

## ករណីសិក្សា៖

## "សូមប្រាប់ពួកគេឱ្យដឹងថា ពួកយើងជាស្ត្រីនៅអ៊ីនហ្គាកំពុងរងទុក្ខវេទនា"[១]

ស្ត្រីនៅតំបន់អ៊ីនហ្គា នៃសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គូ មានធនធានគ្រប់គ្រាន់សម្រាប់រស់ដោយខ្លួនឯង។ ពួកគាត់ដាំផ្លែប៊ឺរ ក្រូច ចេក ដំឡូង សណ្ដែកដី និងសណ្ដែកផ្សេងៗ និងប្រើរុក្ខជាតិជាឱសថសម្រាប់ព្យាបាល ជំងឺ។ គ្រប់យ៉ាងដែលពួកគាត់ប្រើប្រាស់មានប្រភពចេញមកពីក្នុងដីរបស់គាត់។ កសិកម្មគឺជាប្រភពចំណូលតែមួយគត់។ ពួកគាត់ខិតខំធ្វើការណាស់ ប៉ុន្តែទទួលបានគ្រប់គ្រាន់សម្រាប់ត្រឹមតែចិញ្ចឹមជីវិតប៉ុណ្ណោះ។ ប្ដីរបស់ពួកគាត់ភាគច្រើនគ្មានការងារទេ។ ពួកគាត់គិតថា រដ្ឋាភិបាលកុងហ្គូមិនយកចិត្តទុកដាក់លើពួកគាត់ឡើយ ហើយពួកគាត់តែងស្រេកឃ្លានចង់ទទួលបាននូវសេវាសាធារណៈសំខាន់ៗដូចជា ទឹកស្អាត អគ្គិសនី សាលារៀន មន្ទីរពេទ្យ និងផ្លូវថ្នល់។ ប៉ុន្តែស្ត្រីទាំងនេះអាចរស់នៅបានរាប់ទសវត្សរ៍ ដោយសារទឹកទន្លេនិងព្រៃឈើ។

ពួកគាត់រស់នៅក្បែរទឹកជ្រោះអ៊ីនហ្គា និងទឹកជ្ជូរតាមដងទន្លេកុងហ្គូក្រោម។ នៅទសវត្សរ៍ឆ្នាំ១៩៧០និង១៩៨០ រដ្ឋាភិបាលកុងហ្គូបានសង់ទំនប់វារីអគ្គិសនីធំពីរគឺ អ៊ីនហ្គា១ និងអ៊ីនហ្គា២។ រដ្ឋាភិបាលបានសន្យាថា វារីអគ្គិសនីនេះនឹងបង្កើតការងារនិងអគ្គិសនីដល់ភូមិក្នុងតំបន់នេះ។ ជាងបួនទសវត្សរ៍ក្រោយមក ការងារក៏គ្មាន អគ្គិសនីក៏គ្មាន។ ថ្វីបើទំនប់អ៊ីនហ្គា១ និង២គឺជាបរាជ័យដ៏ធំក៏ដោយ រដ្ឋាភិបាលកុងហ្គូមានផែនការសង់គម្រោងអ៊ីនហ្គា៣នៅលើដងទន្លេកុងហ្គូ ឈ្មោះថាគម្រោងហ្គ្រង់អ៊ីនហ្គា។

រដ្ឋាភិបាលកុងហ្គូព្យាយាមកេងប្រវ័ញ្ចសក្ដានុពលទឹកទន្លេម្តងទៀត ដោយសាងសង់ទំនប់វារីអគ្គិសនីធំជាងគេបំផុតនៅលើពិភពលោក។ ក្នុងដំណាក់កាលដំបូង អ៊ីនហ្គា៣បញ្ជូនថាមពលទៅកាន់អ្នកប្រើប្រាស់នៅចម្ងាយរាប់ពាន់គីឡូម៉ែត្រ ចំណែកប្រជាជននៅអ៊ីនហ្គាមិនបានទទួលផលនេះទេ។

នៅឆ្នាំ ២០១៤ ធនាគារពិភពលោកប៉ាន់ប្រមាណថា ទំនប់អ៊ីនហ្គា៣នឹងធ្វើឱ្យបាត់បង់ទីលំនៅប្រជាជនជិត១០.០០០នាក់ រួមមាន ស្ត្រី បុរស និងកុមារ ដែលពឹងផ្អែកទាំងស្រុងលើទឹកទន្លេ ដីធ្លី និងព្រៃឈើ។ ស្ត្រីម្នាក់មកពីភូមិគីលីនកូ និយាយថា "តើយើងនឹងទៅទីណា? បើនៅទីនេះ ទោះគ្មានអ្វីក៏យើងអាចដាំដុះលក់ភោគផល គ្រាន់បានលុយឱ្យកូនទៅសាលារៀនដែរ។"

ស្ត្រីម្នាក់ទៀតនិយាយថា "គេឱ្យការងារដល់អ្នកមកពីស្រុកឆ្ងាយ មិនមែនអ្នកភូមិយើង ប្ដីយើង និងកូនៗយើងទេ"។ ស្ត្រីជាម្ដាយខំចំណាយប្រាក់យ៉ាងច្រើនឱ្យកូនទៅរៀន ប៉ុន្តែកូនៗត្រូវបង្ខំចិត្តមកធ្វើការជួយដាំដុះទៅវិញ។ គ្រប់ភូមិក្នុងតំបន់នេះគ្មានប្រព័ន្ធទឹកទុយយោប្រើទេ។ ឥឡូវនេះ អតីតជំរំកម្មករគីនសាសាបានក្លាយជាតំបន់សម្រាប់ប្រជាជនផ្លាស់ទីលំនៅមកពីអ៊ីនហ្គា១ និង២ អតីតកម្មករ និងកូនចៅរបស់ពួកគាត់។ ក្មេងស្រីៗត្រូវតម្រង់ជួរច្រើនម៉ោងដើម្បីចាំត្រងទឹកស្អាត ពីប្រភពទឹកទុយយោតែមួយគត់នៅក្នុងភូមិដែលមានប្រជាជនជាង១ម៉ឺននាក់។

[១] ករណីសិក្សា ប្រែសម្រួលពីឯកសារក្រោមចំណងជើងថា "ស្ត្រីអ៊ីនហ្គា៖ និមិត្តរូបនៃភាពធន់ទ្រាំ" រៀបរៀងដោយ អានហ្គី អាសានហ្ស៊ី, អង្គការទន្លេអន្តរជាតិ https://www.internationalrivers.org/blogs/337/the-women-of-inga-a-portrait-of-resilience

ដើម្បីស្វែងយល់បន្ថែមអំពីផលប៉ះពាល់ផ្នែកយេនឌ័រដោយសារទំនប់វារីអគ្គិសនី សូមមើលនៅក្នុងឯកសារ *តុល្យភាពជញ្ជីង៖ ការប្រើប្រាស់ការវាយតម្លៃផលប៉ះពាល់ផ្នែកយេនឌ័រនៅក្នុងការអភិវឌ្ឍវារីអគ្គិសនី។*

https://asia.oxfam.org/policy-paper/gender-impact-assessment-gia-manual



ជំរំគីនសាសា កុងហ្គូកណ្តាល, កិច្ចប្រជុំប្រឹក្សាជាមួយស្ត្រី | រូបថតដោយ អង្គការទន្លេអន្តរជាតិ២០១៧



ស្ត្រីចាកចេញពីភូមិបូម៉ា ទៅភូមិពីតា និង ភូមិសេងហ្គី | រូបថតដោយ សីហ្គេ ងីមប៊ី

# ១.២ និយមន័យពាក្យគន្លឹះអំពីយេនឌ័រ

ប្រសិនបើស្ថាប័នដែលធ្វើការជាមួយសហគមន៍រងគ្រោះយល់ដឹងរួមគ្នាអំពីគោលគំនិតនៃវាក្យស័ព្ទស្តីពីយេនឌ័រ វានឹងជួយឱ្យមានការយល់ដឹងអំពីយេនឌ័រនៅក្នុងបរិបទទំនប់ ទន្លេ និងសហគមន៍តាមដងទន្លេ។ ការយល់ដឹងនេះនឹងជួយឱ្យក្រុមការងារទាំងអស់និយាយគ្នាងាយយល់អំពីបញ្ហាយេនឌ័រ ដែលចំនុចនេះគឺជាកត្តាសំខាន់មួយក្នុងពង្រឹងការអនុវត្តយេនឌ័រ។

ជាជំហានដំបូង ចាំបាច់ត្រូវយល់ច្បាស់អំពីពាក្យនិងនិយមន័យសំខាន់ៗមួយចំនួន។ ឧទាហរណ៍ "ភេទ"ខុសគ្នាពី"យេនឌ័រ"។ ភេទសំដៅដល់លក្ខណៈជីវសាស្ត្ររវាងស្ត្រីនិងបុរស ចំណែកយេនឌ័រមានមូលដ្ឋានលើស្ថានភាពវប្បធម៌ សង្គម និងគុណតម្លៃ ដែលកំណត់ជាតួនាទីនិងទំនួលខុសត្រូវរបស់ស្ត្រីនិងបុរស។ "ការយល់ដឹងអំពីតួនាទីផលិតភាព និងតួនាទីពាក់ព័ន្ធនឹងការបន្តពូជ របស់ស្ត្រីនិងបុរស" សុទ្ធតែជាពាក្យគន្លឹះដែលអ្នកអានចាំបាច់ត្រូវយល់ដឹងអំពីអត្ថន័យរបស់វា។

ពាក្យគន្លឹះអំពីយេនឌ័រនិងនិយមន័យរបស់វាមាននៅក្នុងឧបសម្ព័ន្ធទី១។ ចំណែកនៅក្នុងទំព័របន្ទាប់មាននូវនិយមន័យមួយចំនួន ដែលត្រូវបានប្រែសម្រួលចេញពីប្រភពផ្សេងៗ រួមទាំងសទ្ទានុក្រមសមធម៌យេនឌ័ររបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលស្ត្រីនៃអង្គការសហប្រជាជាតិផងដែរ។



ស្ត្រីជនជាតិខូឡុង មកពីខេត្តយូណាន ប្រទេសចិន ដែលបានផ្តល់បទអត្ថាធិប្បាយជាមួយអង្គការទន្លេអន្តរជាតិក្នុងឆ្នាំ២០១៥ អំពីសារៈប្រយោជន៍របស់ទន្លេនូ សម្រាប់ជនជាតិខូឡុង | រូបថតដោយ អង្គការទន្លេអន្តរជាតិ

## យេនឌ័រ

យេនឌ័រមិនសំដៅទៅលើភេទទេ ប៉ុន្តែវាសំដៅដល់បទពិសោធន៍ក្នុងនាមជាបុរសឬជាស្ត្រី និងទស្សនៈដែលសង្គមយល់ឃើញចំពោះតួនាទីនិងទំនួលខុសត្រូវរបស់បុរសនិងស្ត្រី។ ទស្សនៈយល់ឃើញនេះបង្កឱ្យមានការបែងចែករវាងស្ត្រី និង បុរស ហើយសន្មតថាភេទនីមួយៗគួរមានការការគិត ឥរិយាបថ និងការប្រព្រឹត្តទៅតាមបែបបទរៀងខ្លួន។ ទស្សនៈនេះក៏កំណត់នូវរបៀបក្នុងការរៀបចំផ្ទត់សង្គមផងដែរ។ ការបែងចែកយេនឌ័របែបនេះបណ្តាលឱ្យសង្គមកំណត់តម្លៃទៅលើបុរស ស្ត្រី ក្មេងស្រី និងក្មេងប្រុសខុសៗគ្នា និងបែងចែកតួនាទីនិងទំនួលខុសត្រូវទៅតាមនោះ។

សង្គមកំណត់បែងចែកតួនាទីទៅឱ្យមនុស្សដោយផ្អែកទៅតាមយេនឌ័រផ្សេងៗគ្នា។ តម្លៃរបស់តួនាទីទាបឬខ្ពស់ជះឥទ្ធិពលលើលទ្ធភាពក្នុងការទទួលបានផលប្រយោជន៍ ការគ្រប់គ្រង និងឥទ្ធិពលក្នុងការសម្រេចចិត្ត។ ការកំណត់តួនាទីទៅតាមយេនឌ័របែបនេះ អាចបង្កនូវបញ្ហានិងការរើសអើងកាន់តែធ្ងន់ធ្ងរ ជាពិសេសក្នុងករណីដែលមនុស្សមិនកំណត់ខ្លួនឯងទៅតាមអត្តសញ្ញាណភេទណាមួយ ដូចជាអ្នកកែភេទ អ្នកមានសរីរាង្គភេទមិនប្រុសឬមិនស្រីពីកំណើត និងអ្នកដែលគ្មានចំណូលផ្លូវភេទ ជាដើម។

## ទំនាក់ទំនងយេនឌ័រ

សំដៅដល់ទំនាក់ទំនងសង្គមរវាងបុរសនិងស្ត្រី ក្នុងរយៈពេលនិងទីកន្លែងជាក់លាក់។ ទំនាក់ទំនងសង្គមកំណត់នូវកម្រិតឥទ្ធិពលខុសគ្នាក្នុងចំណោមភេទទាំងពីរ។ ស្ត្រីទាំងអស់ ឬបុរសទាំងអស់មិនដូចគ្នាទេ។ ទំនាក់ទំនងយេនឌ័រផ្សារភ្ជាប់និងមានដំណើរប្រទាក់ប្រទងគ្នាជាមួយនឹងអត្តសញ្ញាណសង្គមដទៃទៀត ដូចជា សាសនា និន្នាការនយោបាយ ជនជាតិ ឋានៈក្នុងសង្គម អាយុ និងចំណូលផ្លូវភេទ។

## ការទទួលបាននិងការគ្រប់គ្រងធនធាន

ការទទួលបានសំដៅដល់ឱកាសទទួលបានធនធានដើម្បីប្រើប្រាស់ ចំណែកការគ្រប់គ្រងសំដៅដល់ឥទ្ធិពលក្នុងការសម្រេចចិត្តលើការប្រើប្រាស់ធនធាន និងសិទ្ធិអំណាចក្នុងចាត់ចែងថានរណាអាចប្រើប្រាស់ធនធាននោះបាន។

## ការឆ្លើយតបផ្នែកយេនឌ័រ

សំដៅទៅលើការធ្វើផែនការនិងការអនុវត្តសកម្មភាពកម្មវិធីដែលឆ្លើយតបនឹងបញ្ហាយេនឌ័រ និងលើកកម្ពស់សមភាពយេនឌ័រ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍ដែលគិតគូរអំពីយេនឌ័រនៅក្នុងការអនុវត្តការងារ។

## ការបញ្ជ្រាបយេនឌ័រ

សំដៅដល់ដំណើរការនៃការបញ្ជ្រាបទស្សនៈស្តីពីសមភាពយេនឌ័រទៅក្នុងដំណើរការអភិវឌ្ឍនៅគ្រប់ដំណាក់កាលនិងគ្រប់កម្រិត។ ការបញ្ជ្រាបយេនឌ័រគឺជាយុទ្ធសាស្ត្រមួយដើម្បីសម្រេចបាននូវសមភាពយេនឌ័រ។

## តួនាទីផលិតភាព

សំដៅដល់ការងារដែលបុរសឬស្ត្រីធ្វើ ហើយទទួលបានលទ្ធផលមកវិញជាប្រាក់ឬជាភោគផលមិនមែនប្រាក់ ឧទាហរណ៍ ផលិតកម្មឬសេវាកម្មលើទីផ្សារដែលអាចប្តូរបានជាកម្រៃ និងផលិតកម្មតាមផ្ទះសម្រាប់ប្រើប្រាស់ចិញ្ចឹមជីវិត ឬអាចមានសក្តានុពលប្តូរបានជាកម្រៃ។ តួនាទីផលិតភាពរបស់ស្ត្រីនៅក្នុងផលិតកម្មកសិកម្មមានដូចជា ម្ចាស់ស្រែចំការ កសិករ និងកម្មករ។

## តួនាទីពាក់ព័ន្ធនឹងការបន្តពូជ

សំដៅដល់ការបង្កើតចិញ្ចឹមបីបាច់កូន និងកិច្ចការនានាដែលត្រូវបំពេញក្នុងគោលបំណងថែទាំដល់សមាជិកគ្រួសារនិងសហគមន៍។ តួនាទីនេះមានដូចជា ការងារនៅផ្ទះដែលស្ត្រីធ្វើ ដើម្បីថែទាំនិងកសាងធនធានកម្លាំងពលកម្ម ដូចជា ផ្តល់កំណើតកូន ធ្វើម្ហូប រើសអុស ដងទឹក មើលកូន អប់រំណែនាំ និងថែទាំសុខភាពសមាជិកគ្រួសារ។

## ផ្នែកទី២

# ការបញ្ជ្រាបយេនឌ័រ និងការវាយតម្លៃយេនឌ័រសម្រាប់ស្ថាប័ន



សម្រាប់ស្ថាប័នដែលធ្វើការជាមួយសហគមន៍ ការបញ្ជ្រាបយេនឌ័រសរបញ្ជាក់ឱ្យឃើញថា អន្តរាគមន៍របស់ស្ថាប័ននោះមានបំណងផ្តល់ផលប្រយោជន៍ដល់ទាំងស្ត្រីនិងបុរស។ មានន័យថា ស្ថាប័នមិនចូលរួមចំណែកក្នុងការពង្រីកបញ្ហាវិសមភាពដែលមានស្រាប់ទេ ផ្ទុយទៅវិញស្ថាប័ននឹងលើកកម្ពស់ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី។

ការបញ្ជ្រាបយេនឌ័រគឺជាការដាក់បញ្ចូលនូវទស្សនៈស្តីពីសមភាពយេនឌ័រទៅក្នុងដំណើរការនិងវិធីសាស្ត្រអនុវត្តការងារនៅគ្រប់ដំណាក់កាល និងគ្រប់កម្រិត។ ការបញ្ជ្រាបយេនឌ័រគឺជាយុទ្ធសាស្ត្រមួយដើម្បីសម្រេចបាននូវសមភាពយេនឌ័រ។

ការបញ្ជ្រាបយេនឌ័រអាចជាកត្តារួមចំណែកយ៉ាងសំខាន់ក្នុងការសម្រេចបាននូវយុត្តិធម៌សង្គម ពីព្រោះវាដោះស្រាយនូវបញ្ហាវិសមភាព។ វិសមភាពកើតមានដោយសារកង្វះឱកាសឬភាពជាតំណាង កង្វះឥទ្ធិពល និងតួនាទីក្នុងការធ្វើសេចក្តីសម្រេចក្នុងស្ថាប័ននិងសង្គម។ អង្គការសហប្រជាជាតិបានគូសបញ្ជាក់ថា ការបញ្ជ្រាបយេនឌ័រមិនមែនជាគោលដៅចុងក្រោយនោះទេ ប៉ុន្តែវាគឺជាការផ្សំបញ្ចូលគ្នារវាងយុទ្ធសាស្ត្រ ដំណើរការ និងការអន្តរាគមន៍ ដែលដោះស្រាយបញ្ហាជាប្រព័ន្ធដើម្បីឆ្ពោះទៅរកសមភាពនៅគ្រប់កម្រិត និងក្នុងសកម្មភាពចម្រុះ ដូចជាគោលនយោបាយ ការស្រាវជ្រាវ ការតស៊ូមតិ ច្បាប់ ការបែងចែកធនធាន ការរៀបចំ និងការអនុវត្តគម្រោង។

នៅក្នុងផ្នែកនេះ យើងផ្តល់ការណែនាំមួយចំនួនអំពីវិធីវាយតម្លៃការអនុវត្តយេនឌ័រ និងការបញ្ជ្រាបយេនឌ័រនៅក្នុងយុទ្ធនាការទំនប់និងទន្លេ។ ក្រៅពីនេះ យើងនឹងពិនិត្យមើលផងដែរទៅលើយុទ្ធសាស្ត្រ សកម្មភាព និងកត្តាផ្សេងទៀតដែលអាចជួយកែលម្អការអនុវត្តយេនឌ័ររបស់អ្នក។

២ http://www.un.org/womenwatch/osagi/gendermainstreaming.htm



ទន្លេមេគង្គនៅភាគខាងជើងប្រទេសឡាវ។ ទន្លេមេគង្គគឺជាប្រភពនៃសន្តិសុខស្បៀងដ៏សំខាន់សម្រាប់ប្រជាជនជាង ៦០លាននាក់នៅតាមបណ្តាប្រទេសខ្សែទឹកខាងក្រោម ដូចជា ឡាវ ថៃ កម្ពុជា និងវៀតណាម | រូបថតដោយ អង្គការទន្លេអន្តរជាតិ ឆ្នាំ២០០៨

# ការអនុវត្តការបញ្ជ្រាបយេនឌ័រ៖ ការចាប់ផ្តើម

យើងវាយតម្លៃយេនឌ័រដើម្បីវាស់វែងមើលថា តើស្ថាប័នកំពុងបញ្ជ្រាបយេនឌ័រទៅក្នុងការងាររបស់ខ្លួនបានប្រសើរកម្រិតណា ហើយតើស្ថាប័នមានមូលដ្ឋានគ្រឹះចាំបាច់ក្នុងការបញ្ជ្រាបយេនឌ័រដោយជោគជ័យឬទេ ដូចជា គោលនយោបាយបញ្ជ្រាប ជំនាញនិងចំណេះដឹងរបស់បុគ្គលិកអំពីយេនឌ័រ និងថវិកាសម្រាប់យេនឌ័រ។

ដើម្បីវាយតម្លៃយេនឌ័រសម្រាប់ស្ថាប័នរបស់អ្នក ចាំបាច់គួរពិចារណាលើសមាសធាតុពីរដែលលើកកម្ពស់ឱ្យគ្នាទៅវិញទៅមក៖

i. ពិនិត្យមើលទៅលើស្ថាប័ន គោលនយោបាយ ធនធានមនុស្ស ធនធានផ្សេងៗ និងចំណេះដឹង

ii. ពិនិត្យមើលទៅលើយុទ្ធនាការដែលកំពុងអនុវត្តថាតើការបញ្ជ្រាបយេនឌ័របានប្រសើរកម្រិតណា។

ឧបសម្ព័ន្ធទី២បង្ហាញអំពីការវាយតម្លៃយេនឌ័រសម្រាប់ស្ថាប័ន ចំណែកឧបសម្ព័ន្ធទី៣បង្ហាញអំពីការវាយតម្លៃយេនឌ័រសម្រាប់យុទ្ធនាការ។ ឧបសម្ព័ន្ធទាំងពីរនេះមាននូវសំណួរមួយចំនួនសម្រាប់ជាជំនួយក្នុងការឆ្លុះបញ្ចាំង និងទម្រង់គំរូសម្រាប់ចងក្រងលទ្ធផលនៃការវាយតម្លៃ។ ការវាយតម្លៃទាំងពីរនេះគួរតែធ្វើឡើងដោយមានការចូលរួមពីបុគ្គលិកនិងដៃគូពាក់ព័ន្ធ ចំណែកការវាយតម្លៃយុទ្ធនាការ គួរមានការចូលរួមពីស្ត្រីនិងបុរសមកពីសហគមន៍ដែលអ្នកធ្វើការជាមួយ។ នៅក្នុងនោះមានសំណួរសម្រាប់ជាជំនួយក្នុងការឆ្លុះបញ្ចាំង ការពិភាក្សា និងផែនការសកម្មភាព។ អ្នកគួរប្រើលទ្ធផលនៃការវាយតម្លៃទាំងនេះដើម្បីស្វែងរកគម្លាតនៃការអនុវត្តយេនឌ័រ និងរៀបចំសកម្មភាពអាទិភាពដើម្បីបំពេញកង្វះចន្លោះទាំងនោះ។ គួរកត់ត្រាបញ្ចូលសកម្មភាពអាទិភាពឱ្យបានច្បាស់ ទៅក្នុងផែនការសកម្មភាពយេនឌ័រ ដើម្បីងាយក្នុងការតាមដានវឌ្ឍនភាព។



តំបន់ដីលិចទឹកហាដេចា-ង្គូរ ប្រទេសនីហ្សេរីយ៉ា។ ស្ត្រីនៅតំបន់កូម៉ាដូហ្គូនៃអាងទន្លេយូបេ | រូបថតដោយអង្គការទន្លេអន្តរជាតិ ឆ្នាំ២០១៥



តំបន់ដីលិចទឹកហាដេចា-ង្គូ។ ប្រជាជនឆ្លងទឹកមកលក់ផលដំណាំរបស់ពួកគាត់ | រូបថតដោយអង្គការទន្លេអន្តរជាតិ ឆ្នាំ២០១៥

បន្ទាប់ពីវាយតម្លៃយេនឌ័រសម្រាប់ស្ថាប័ននិងសម្រាប់យុទ្ធនាការ និងធ្វើផែនការសកម្មភាពយេនឌ័ររួច ស្ថាប័នអាចៈ

- បន្តការសន្ទនាស្តីពីការអនុវត្តយេនឌ័ររបស់ស្ថាប័ន និងវិធីបំពេញចន្លោះខ្វះខាតនៅក្នុងការអនុវត្ត។
- រៀបចំវេទិកាដើម្បីដោះស្រាយគម្លាតអាទិភាព។
- តាមដានវឌ្ឍនភាពនៃការអនុវត្តសកម្មភាព និងផែនការសកម្មភាពយេនឌ័រ។
- រៀបចំផែនការដើម្បីបញ្ជ្រាបយេនឌ័រឱ្យបានប្រសើរជាងមុន ទៅក្នុងការរៀបចំនិងអនុវត្តយុទ្ធនាការ និងព្រមព្រៀងលើសកម្មភាពអាទិភាព។
- បង្កើតសូចនាករនិងក្របខ័ណ្ឌត្រួតពិនិត្យ ដើម្បីអនុញ្ញាតឱ្យបុគ្គលិក ធ្វើការវាយតម្លៃភាពជោគជ័យនៃយុទ្ធនាការក្នុងការបំពេញតម្រូវការនិងផលប្រយោជន៍របស់ស្ត្រីនិងបុរស។
- គិតគូរផ្តល់ការបណ្តុះបណ្តាលនិងការអភិវឌ្ឍវិជ្ជាជីវៈផ្នែកយេនឌ័រដល់បុគ្គលិកយុទ្ធនាការ ដៃគូ និងតំណាងសហគមន៍។

ប្រសិនបើអ្នករកឃើញថាមានគម្លាតនៅក្នុងគោលនយោបាយយេនឌ័រ ឬវិធីសាស្ត្របញ្ជ្រាបយេនឌ័រ ចូរអនុវត្តតាមយុទ្ធសាស្ត្រនិងសកម្មភាពសាមញ្ញៗមួយចំនួនដូចខាងក្រោម។

## ចូរពិចារណាៈ

- រកដៃគូថ្មីឬអ្នកជំនាញយេនឌ័រមកជួយបំពេញចន្លោះខ្វះខាតនៃជំនាញ។
- គិតគូរពីវេទិកាសម្រាប់ផ្តល់ឱកាសកែលម្អការអនុវត្តយេនឌ័រ ដូចជា ការបណ្តុះបណ្តាលជំនាញយេនឌ័រ។
- ធានាថាស្ត្រីនិងបុរសចូលរួមស្មើភាពគ្នានិងមានសមាមាត្រយេនឌ័រ នៅក្នុងរាល់ការធ្វើសេចក្តីសម្រេចគ្រប់កម្រិត។
- គាំទ្រឱ្យមានជនបង្គោលឬជើងឯកយេនឌ័រម្នាក់ឬច្រើននាក់ នៅក្នុងស្ថាប័នរបស់អ្នក។ ពួកគាត់អាចដឹកនាំការងារយេនឌ័រមួយចំនួន ក៏ដូចជាគាំទ្របុគ្គលិកដទៃទៀតដើម្បីអភិវឌ្ឍចំណេះដឹងនិងជំនាញយេនឌ័រ។
- បង្កើតក្រុមការងារយេនឌ័រឬក្រុមសហគមន៍យេនឌ័រដើម្បីគាំទ្រដល់បុគ្គលិកក្នុងការអភិវឌ្ឍចំណេះដឹងនិងជំនាញយេនឌ័រ។
- ធានាថាស្ត្រីនិងបុរសបានចូលរួមស្មើគ្នាក្នុងក្រុមការងារ ក្រុមគម្រោង និងក្រុមប្រឹក្សា ក៏ដូចជានៅពេលរៀបចំកម្មវិធីនានា ឧ. នៅពេលជ្រើសរើសវាគ្មិន ជាដើម។
- បែងចែកទំនួលខុសត្រូវដល់បុគ្គលិកនិងអ្នកគ្រប់គ្រងក្នុងការអនុវត្តសកម្មភាពអាទិភាព។

## ផ្នែកទី៣

# ការវិភាគយេនឌ័រ

## ៣.១ តើការវិភាគយេនឌ័រគឺជាអ្វី

ការវិភាគយេនឌ័រគឺជាដំណើរការនៃការពិនិត្យមើលទៅលើតួនាទីនិងទំនួលខុសត្រូវរបស់ស្ត្រីនិងបុរស ទំនាក់ទំនងរវាងស្ត្រីនិងបុរស និងវិសមភាពនៅក្នុងទំនាក់ទំនងរបស់ពួកគេ។ ការវិភាគយេនឌ័រលើកកម្ពស់សមភាពយេនឌ័រតាមរយៈការពិនិត្យមើលទំនាក់ទំនងរវាងឥទ្ធិពលនៅក្នុងគ្រួសារ ក្នុងស្ថាប័ន និងក្នុងសង្គម។

ការវិភាគយេនឌ័រគឺជាចំណុចចាប់ផ្តើមដ៏សំខាន់មួយក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងការងារសហគមន៍។ គេអាចប្រើការវិភាគយេនឌ័រដើម្បីស្វែងយល់ពីទំនាក់ទំនងនិងវិសមភាពរវាងបុរសនិងស្ត្រីនៅក្នុងសហគមន៍រងគ្រោះដោយសារគម្រោងទំនប់ និងស្វែងយល់មើលថាតើគម្រោងទំនប់នឹងផ្លាស់ប្តូរទំនាក់ទំនងនិងបង្កើនវិសមភាពអ្វីខ្លះ។



ស្ត្រីម្នាក់កំពុងបេះព្រលឹត នៅទន្លេមេគង្គ | រូបថតដោយ អង្គការអុកស្វាម





ស្ត្រីម្នាក់កំពុងទៅប្រមូលផលដំណាំ នៅភូមិវូស៊ី នៃតំបន់អ៊ីនហ្គា | រូបថតដោយ អង្គការទន្លេអន្តរជាតិ

## ករណីសិក្សា៖

# ស្វែងយល់អំពីជីវិតប្រចាំថ្ងៃរបស់ស្ត្រីកុងហ្គោ នៅជុំវិញតំបន់ទំនប់វារីអគ្គិសនីអ៊ីនហ្គា

សហគមន៍ដែលរងផលប៉ះពាល់ពីទំនប់វារីអគ្គិសនីអ៊ីនហ្គា៣ ធ្លាប់ទទួលរងគ្រោះដោយសារទំនប់វារីអគ្គិសនីមុនៗរួចទៅហើយ ហើយភាគច្រើនបានផ្លាស់ប្តូរទីលំនៅថ្មីមកទីនេះ កាលពីប៉ុន្មានទសវត្សរ៍មុន។ ខាងក្រោមនេះគឺជាសកម្មភាពប្រចាំថ្ងៃរបស់ស្ត្រីនៅអ៊ីនហ្គា។

ជាធម្មតា ស្ត្រីនៅអ៊ីនហ្គាក្រោកពីដំណេកនៅម៉ោង៤ព្រឹក និងបញ្ចប់កិច្ចការនៅម៉ោង១០យប់ ហើយថ្ងៃខ្លះពួកគាត់ត្រូវធ្វើការច្រើនម៉ោងជាងនេះ។ នៅថ្ងៃណាដែលពួកគាត់ត្រូវទៅរកអុសនៅក្នុងព្រៃ ពួកគាត់ច្រើនមកដល់ផ្ទះវិញនៅពេលយប់ រៀបចំអាហារទទួលទាន និងចូលដំណេកយប់ជ្រៅ។ ការប្រកបកិច្ចការចិញ្ចឹមជីវិតរបស់ពួកគាត់មានដូចជា៖

**ធ្វើស្រែចំការ៖** ស្ត្រីខ្លះធ្វើស្រែចំការជាមួយប្តីនិងក្រុមគ្រួសារគាត់ ប៉ុន្តែស្ត្រីជាច្រើន ជាពិសេសស្ត្រីមេម៉ាយ និងស្ត្រីនៅលីវ ត្រូវធ្វើកិច្ចការនេះដោយខ្លួនឯង។ ស្ត្រីមេម៉ាយនិងស្ត្រីនៅលីវមានបន្ទុកគ្រួសារធ្ងន់ ពីព្រោះពួកគាត់ត្រូវធ្វើកិច្ចការដំណាំដាំដុះដោយខ្លួនឯង ដោយសារពុំមានលទ្ធភាពចំណាយលើកម្លាំងពលកម្មបន្ថែម។

**ជួញត្រី៖** អ្នកជួញត្រីភាគច្រើនមកពីភូមិម៉ានស៊ី ដែលស្ថិតនៅប៉ែកខាងក្រោមនៃតំបន់អ៊ីនហ្គា។ ពួកគាត់ហាក់ដូចជាមានជីវភាពនិងគុណភាពជីវិតប្រសើរជាងក្រុមផ្សេង ប៉ុន្តែពួកគាត់បានត្អូញត្អែរថាត្រូវធ្វើកិច្ចការច្រើនម៉ោង បរិមាណត្រីក្នុងទន្លេកុងហ្គោកំពុងថយចុះ ហើយត្រីភាគច្រើនតូចៗនិងគុណភាពមិនល្អ។ ជាទូទៅពួកគាត់មានទូរស័ព្ទដៃផ្ទាល់ខ្លួន។ ជីវិតហាក់ដូចជាមានភាពល្អប្រសើរ សម្រាប់សហគមន៍ដែលនៅឆ្ងាយពីអ៊ីនហ្គា។

**ប្រមាញ់សត្វ៖** ការបរបាញ់សត្វភាគច្រើនគឺជាការងារបុរស ប៉ុន្តែស្ត្រីក៏ទទួលបានផលប្រយោជន៍ពីការប្រកបសកម្មភាពចិញ្ចឹមជីវិតនេះដែរ តាមរយៈការទទួលបាននូវអាហារនិងតម្រូវការប្រូតេអ៊ីននៅក្នុងក្រុមគ្រួសារ។ ចំពោះសាច់សត្វដែលនៅសល់ ស្ត្រីអាចយកទៅលក់នៅក្នុងសហគមន៍គាត់។

**លក់ដូរ៖** នេះគឺជាកិច្ចការចិញ្ចឹមជីវិតដែលភាគច្រើនស្ត្រីជាអ្នកធ្វើ។ អ្នកលក់ដូរធ្វើការច្រើនម៉ោង និងគ្មានម៉ោងចាប់ផ្តើម ឬម៉ោងឈប់ទៀងទាត់ទេ។ ពួកគាត់បើកលក់នៅពេលមានមនុស្សមកទិញ និងឈប់លក់នៅពេលគេឈប់មកទិញ។ វាគឺជារបរលក់ដូរតាមភូមិ ដែលមិនសូវទទួលបានចំណូលច្រើនទេ ពីព្រោះចំណេញតិចតួច។

តាមរយៈការយល់ដឹងអំពីតួនាទីនិងទំនួលខុសត្រូវរបស់ស្ត្រីនិងបុរស ទំនាក់ទំនងរវាងពួកគាត់ និងវិសមភាពនៅក្នុងទំនាក់ទំនង គេអាចស្វែងយល់បានអំពីផលប៉ះពាល់ផ្សេងគ្នារបស់ទំនប់ទៅលើបុរស និងស្ត្រី។ ការវិភាគយេនឌ័រអាចធានាថា ស្ថាប័នយកចិត្តទុកដាក់ជាសំខាន់លើបញ្ហានិងកង្វល់របស់ស្ត្រីនិងបុរស និងធានាថាមានភាពជាអ្នកដឹកនាំនិងការចូលរួមរបស់ស្ត្រីនៅក្នុងយុទ្ធនាការទំនប់របស់ខ្លួន។

# ៣.២ ជំហានក្នុងការវិភាគយេនឌ័រ

អង្គការទន្លេអន្តរជាតិសូមផ្តល់ជាអនុសាសន៍នូវជំហានចំនួន៦ ក្នុងការវិភាគយេនឌ័រ ដើម្បីស្វែងយល់ថាតើគម្រោងទំនប់មានឥទ្ធិពលលើស្ត្រីនិងបុរសយ៉ាងដូចម្តេច ហើយស្ថាប័នគួរគិតគូរយ៉ាងណាអំពីផលប៉ះពាល់នោះ និងគួរបញ្ចូលតម្រូវការនិងផលប្រយោជន៍របស់ស្ត្រីនិងបុរសទៅក្នុងយុទ្ធនាការដោយរបៀបណា។ ការវិភាគយេនឌ័រគួរធ្វើឡើងដោយមានការចូលរួមពីសហគមន៍រងផលប៉ះពាល់ និងមានការចងក្រងទុកជាឯកសារផងដែរ។ ដំណើរការវិភាគអាចធ្វើឡើងតែមួយដងក្នុងកិច្ចប្រជុំមួយ ឬធ្វើឡើងច្រើនដង ជាដំណាក់កាលបន្តបន្ទាប់ ក្នុងរយៈពេលវែង។

**ជំហានទាំង៦មានដូចខាងក្រោម៖**

1. ស្វែងយល់ថាស្ត្រីផ្តល់តម្លៃបែបណា ហើយបុរសផ្តល់តម្លៃបែបណាទៅឱ្យទន្លេ
2. ស្វែងយល់ពីការបែងចែកយេនឌ័រក្នុងពលកម្ម (ការងារស្ត្រី និងការងារបុរស)
3. ស្វែងយល់ថា តើនរណាមានសិទ្ធិប្រើប្រាស់ និងចាត់ចែងធនធានក្នុងគ្រួសារនិងសហគមន៍
4. ស្វែងយល់ពីឧបសគ្គនិងដំណោះស្រាយ ចំពោះការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត
5. ស្វែងយល់ពីតម្រូវការយេនឌ័រជាក់ស្តែង និងផលប្រយោជន៍យេនឌ័រជាយុទ្ធសាស្ត្រសម្រាប់ស្ត្រី
6. ស្វែងយល់ពីផលប៉ះពាល់នៃគម្រោងទំនប់ដែលបានស្នើ ដែលអាចកើតមានទៅលើស្ត្រីនិងបុរស

ឯកសារឧបសម្ព័ន្ធទី៤ដល់ទី៩ មានឧបករណ៍ ទម្រង់គំរូ និងសំណួរសំខាន់ៗដើម្បីជាជំនួយដល់ស្ថាប័នក្នុងការប្រមូលព័ត៌មានសម្រាប់ជំហានទាំង៦ដែលបានរៀបរាប់ខាងលើ (សេចក្តីពណ៌នាសង្ខេបអំពីជំហានទាំង៦មាននៅក្នុងទំព័របន្តបន្ទាប់)។

យើងសូមផ្តល់អនុសាសន៍ឱ្យប្រមូលព័ត៌មានសម្រាប់ជំហាននីមួយៗតាមរយៈការពិភាក្សាដោយមានការសម្របសម្រួល (ឬការពិភាក្សាក្រុមដោយផ្តោតលើប្រធានបទជាក់លាក់)។ ការសន្ទនាអាចធ្វើឡើងដាច់ដោយឡែករវាងស្ត្រីនិងបុរស។ ក្រៅពីនេះ អ្នកអាចប្រមូលព័ត៌មានតាមរយៈការសម្ភាសន៍ ឬការស្ទង់មតិជាមួយស្ត្រី និងបុរសដែលមកពីសហគមន៍ ហើយពួកគាត់ក៏អាចអ្នកជួយក្នុងការប្រមូល និងវិភាគព័ត៌មានផងដែរ។

ជាកិច្ចសំខាន់ណាស់ដែលយើងត្រូវទទួលស្គាល់ថា ការវិភាគយេនឌ័រមិនមែនគ្រាន់តែជាការងារបច្ចេកទេសដែលត្រូវបំពេញទេ។ ផ្ទុយទៅវិញ ការវិភាគយេនឌ័រគឺជាដំណើរការនៃការពង្រឹងសិទ្ធិអំណាច និងផ្តល់លទ្ធភាពក្នុងការកែប្រែឥទ្ធិពលនៅក្នុងសហគមន៍ និងជាមួយភាគីពាក់ព័ន្ធខាងក្រៅ។

ការវិភាគយេនឌ័រគួរអនុវត្តទៅតាមគោលការណ៍សំខាន់ៗមួយចំនួនដូចខាងក្រោម៖

- មានការចូលរួម ស្វែងរក និងដោះស្រាយជម្នះឧបសគ្គដែលរារាំងការចូលរួមពេញលេញរបស់ស្ត្រីក្នុងការវិភាគយេនឌ័រ
- អនុញ្ញាតឱ្យមានការវិភាគ រៀនសូត្រ និងធ្វើសកម្មភាពរួមគ្នាជាសមូហភាព
- ផ្តោតលើក្រុមប្រជាជនដែលបាត់បង់ឱកាសឬងាយរងគ្រោះខ្លាំងនៅក្នុងសហគមន៍
- ពិចារណានិងពិនិត្យមើលលើកត្តាចម្រុះដែលកំណត់នូវអត្តសញ្ញាណ ដូចជា ឋានៈ យេនឌ័រ ជនជាតិ សមត្ថភាពចលភាព ។ល។ ដែលជាកត្តាដែលអាចកំណត់ ឥទ្ធិពល សិទ្ធិអំណាច ភាពងាយរងគ្រោះ និងកម្រិតនៃការរើសអើង
- អនុលោមទៅតាមសិទ្ធិមនុស្ស និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ (ការរួមបញ្ចូល ការចូលរួម ការពង្រឹងសិទ្ធិអំណាច តម្លាភាព ការយកចិត្តទុកដាក់ចំពោះជនងាយរងគ្រោះ និងការមិនរើសអើង)
- សំដៅឆ្ពោះទៅរកការផ្លាស់ប្តូរជាវិជ្ជមាន

ការវិភាគយេនឌ័រ (និងដំណើរការរៀបចំយុទ្ធនាការ) គួរមានការចូលរួមពីបុរស និងលើកទឹកចិត្តឱ្យពួកគាត់គាំទ្រដល់សិទ្ធិស្ត្រី និងការចូលរួមនិងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងយុទ្ធនាការទំនប់និងទន្លេ។ យោងតាមបទពិសោធន៍របស់យើងជាមួយសហគមន៍នៅប្រទេសកុងហ្គោ ការចូលរួមរបស់បុរសនៅក្នុងការវិភាគយេនឌ័របានធ្វើឱ្យពួកគាត់មើលឃើញ និងទទួលស្គាល់នូវការងារ សំឡេង និងការចូលរួមរបស់ស្ត្រី ហើយបុរសជាច្រើនបានបង្ហាញការគាំទ្រចំពោះសកម្មភាពស្ត្រីនៅក្នុងកិច្ចការទំនប់និងទន្លេ។

ប្រសិនបើបុរសមិនគាំទ្រការចូលរួមរបស់ស្ត្រីនៅក្នុងការវិភាគយេនឌ័រ ឬក្នុងយុទ្ធនាការទំនប់និងទន្លេទេ ចាំបាច់អាចនឹងត្រូវមានកិច្ចប្រឹងប្រែងពិសេសដើម្បីស្វែងរកដំណោះស្រាយទៅលើបញ្ហានេះ ដែលអាចមានដូចជា៖

- ការប្រជុំសហគមន៍ដែលមានក្រុមអ្នកដឹកនាំជាស្ត្រី ធ្វើការជាមួយបុរសដែលគាំទ្រសិទ្ធិស្ត្រី
- វគ្គបណ្តុះបណ្តាល ឬការបង្ហាត់សម្រាប់បុរស
- សកម្មភាពវប្បធម៌ ការសម្តែងរឿងតាមផ្លូវ ក្បួនដង្ហែព្រឹត្តិការណ៍សាធារណៈ ផ្ទាំងរូបភាព និងកម្មវិធីផ្សាយតាមវិទ្យុ ដែលលើកកម្ពស់សមភាពយេនឌ័រ

ការចូលរួមរបស់បុរសមានសារៈសំខាន់ណាស់ ហើយអ្វីដែលរឹតតែសំខាន់ខ្លាំងនោះគឺ ការបង្កើតនិងផ្តល់ឱកាសឬទីកន្លែងសម្រាប់តែស្ត្រី។ ជាធម្មតា កាលណាមានវត្តមានបុរស ស្ត្រីមិនអាចចូលរួម ឬចូលរួមមិនប្រកបដោយអត្ថន័យ នៅក្នុងកិច្ចពិគ្រោះយោបល់ឬការវិភាគយេនឌ័របានទេ។ កត្តារារាំងការចូលរួមរបស់ស្ត្រីមានដូចជា ច្បាប់ទម្លាប់សង្គមដែលរើសអើង រឹតត្បិតតួនាទីស្ត្រីឱ្យនៅតែជុំវិញកិច្ចការផ្ទះ ការរំពឹងរបស់សង្គមដែលគិតថាមានតែបុរសទេដែលគួរតស៊ូមតិជំនួសគ្រួសារនិងសហគមន៍ អំពើហិង្សាលើស្ត្រី និងកម្រិតនៃការអប់រំរបស់ស្ត្រីនៅទាប។ ហេតុដូច្នេះ ការបង្កើតឱ្យមានការជួបជុំសម្រាប់តែស្ត្រី អាចជួយដោះស្រាយឧបសគ្គទាំងនេះ និងធានាឱ្យមានការចូលរួមពីស្ត្រីប្រកបដោយអត្ថន័យ នៅក្នុងការវិភាគយេនឌ័រនិងការរៀបចំយុទ្ធនាការ។ ក្រៅពីនេះ កត្តាដទៃទៀតដែលជំរុញឱ្យស្ត្រីចូលរួមមានដូចជា អ្នកសម្របសម្រួលស្រី អ្នកបកប្រែស្រី ការរៀបចំកន្លែងដែលគិតគូរដល់កូនតូចរបស់គាត់ និងការផ្តល់ថវិកាដើម្បីទូទាត់ជាមួយនឹងការដែលគាត់ត្រូវឈប់ពីការងារគាត់ដើម្បីមកចូលរួម។

### ជំហានទី១៖ ស្វែងយល់ថាស្ត្រីផ្តល់តម្លៃបែបណា ហើយបុរសផ្តល់តម្លៃបែបណាទៅឱ្យទន្លេ

នៅក្នុងជំហាននេះ យើងសុំឱ្យស្ត្រីនិងបុរសប្រាប់អំពីសារៈសំខាន់របស់ទន្លេចំពោះពួកគាត់ ហើយគុណប្រយោជន៍អ្វីដែលពួកគាត់ទទួលបានពីប្រព័ន្ធអេកូឡូស៊ីរបស់ទន្លេ។ គុណប្រយោជន៍អាចមានដូចជា ប្រភពសម្រាប់ចិញ្ចឹមជីវភាព សន្តិសុខស្បៀង (នេសាទ និងកសិកម្ម) ទឹកបរិភោគ ទឹកងូត ទឹកសំអាត ផ្លូវដឹកជញ្ជូន (ទំនិញ និងសេវាកម្ម ឬមនុស្ស) និងសម្រាប់គោលបំណងវប្បធម៌និងសាសនា។ ជំហាននេះគឺជាដំណាក់កាលណែនាំ ដែលអាចប្រមូលនូវព័ត៌មានថ្មីៗដែលយើងមិនបានរំពឹងទុក ចំណែកជំហានទី២និងទី៣នឹងប្រមូលព័ត៌មានបន្ថែមដោយពិនិត្យទៅលើបញ្ហាជាក់លាក់។

### ជំហានទី២៖ ស្វែងយល់ពីការបែងចែកយេនឌ័រក្នុងកិច្ចការពលកម្ម

ជំហាននេះប្រមូលព័ត៌មានដើម្បីស្វែងយល់ពីការបែងចែកយេនឌ័រក្នុងកិច្ចការពលកម្ម (ការងារស្ត្រី និងការងារបុរស) ដូចជា អ្នកណាធ្វើអ្វីខ្លះ រយៈពេលប៉ុន្មាន ពេលណា (ឧ. រាល់ថ្ងៃ ឬតាមរដូវកាល) ហើយស្ត្រីនិងបុរសមានធ្វើការងារទាំងនោះជាមួយគ្នាឬទេ។ យើងចង់សំដៅដល់ទាំងការងារផលិតភាព ទាំងការងារពាក់ព័ន្ធនឹងការបន្តពូជ និងការងារសហគមន៍ ហើយរាប់បញ្ចូលទាំងការងារមានកម្រៃ និងការងារគ្មានកម្រៃផងដែរ។ យើងនឹងមើលឃើញច្បាស់ថា ការងារពាក់ព័ន្ធនឹងការបន្តពូជ (ការងារថែទាំគ្មានកម្រៃ) ភាគច្រើនត្រូវបានគេគិតថាជា "ការងាររបស់ស្ត្រី"។ ក្រៅពីនេះ គួរតែស្វែងយល់ពីទីកន្លែងធ្វើការ ដូចជា នៅផ្ទះ នៅស្រែចំការ នៅទន្លេ នៅផ្សារ ឬនៅកន្លែងផ្សេងទៀត។ ទិន្នន័យដែលប្រមូលបានក្នុងជំហាននេះជួយឱ្យសហគមន៍និងស្ថាប័នដែលគាំទ្រពួកគាត់ អាចស្វែងយល់បានកាន់តែច្បាស់ថា តើគម្រោងទំនប់អាចមានឥទ្ធិពលអ្វីខ្លះទៅលើការងារស្ត្រីនិងបុរស ឧ. កំណើនបន្ទុកលើស្ត្រីនិងបុរស ឬការធ្លាក់ចុះនូវចំណូលរបស់ស្ត្រីនិងបុរស ជាដើម។

## ជំហានទី៣៖ ស្វែងយល់ថា តើនរណាមានសិទ្ធិប្រើប្រាស់និងចាត់ចែងធនធានក្នុងគ្រួសារនិងសហគមន៍

ជំហាននេះប្រមូលព័ត៌មានអំពីអ្នកមានសិទ្ធិប្រើប្រាស់ ចាត់ចែង ឬគ្រប់គ្រងធនធានក្នុងគ្រួសារ និងសហគមន៍ ហើយបុរសនិងស្ត្រីទទួលបានផលប្រយោជន៍អ្វីខ្លះពីធនធានទាំងនេះ។ ធនធានសំដៅដល់ ដី ព្រៃឈើ ទឹក និងជលផល ចំណែកផលប្រយោជន៍អាចមានដូចជា ស្បៀងសម្រាប់បរិភោគឬលក់ ប្រាក់ចំណូល ឋានៈ ឥទ្ធិពល និងការទទួលស្គាល់។ ព័ត៌មានទាំងនេះអនុញ្ញាតឱ្យសហគមន៍និងស្ថាប័នស្វែងយល់កាន់តែច្បាស់ថាតើនរណាអាចនឹងត្រូវរងផលប៉ះពាល់ និងរងប៉ះពាល់របៀបណា ប្រសិនបើធនធានត្រូវបានបំផ្លាញ កាន់កាប់ ឬផ្ទេរទៅឱ្យក្រុមដទៃទៀត។

## ជំហានទី៤៖ ស្វែងយល់ពីឧបសគ្គនិងដំណោះស្រាយចំពោះការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត

ជាកិច្ចចាំបាច់ណាស់ដែលយើងត្រូវស្វែងយល់ថា នរណាជាអ្នកសម្រេចចិត្តក្នុងគ្រួសារ សហគមន៍ និងសង្គម នរណាត្រូវបានគេដកចេញឬបិទឱកាស ហើយតើធ្វើយ៉ាងណាដើម្បីរួមបញ្ចូលពួកគាត់ក្នុងការសម្រេចចិត្តនៅក្នុងសហគមន៍។ ជំហាននេះស្វែងយល់អំពីឧបសគ្គចំពោះការចូលរួមរបស់ស្ត្រីក្នុងការសម្រេចចិត្ត។ វានឹងជួយក្នុងការរៀបចំយុទ្ធសាស្ត្រដោះស្រាយឧបសគ្គរារាំងការចូលរួមរបស់ស្ត្រី និងជួយទាមទារឱ្យមានការចូលរួមរបស់ស្ត្រីក្នុងសេចក្តីសម្រេចចិត្តសាធារណៈអំពីការសាងសង់ទំនប់។ ការទាមទារនូវការចូលរួមរបស់ស្ត្រីក៏អាចជាគោលដៅមួយសម្រាប់យុទ្ធនាការដែរ។

## ជំហានទី៥៖ ស្វែងយល់ពីតម្រូវការយេនឌ័រជាក់ស្តែង និងផលប្រយោជន៍យេនឌ័រជាយុទ្ធសាស្ត្រសម្រាប់ស្ត្រី

ជំហាននេះមានគោលបំណងស្វែងយល់ពីតម្រូវការយេនឌ័រជាក់ស្តែង និងផលប្រយោជន៍យេនឌ័រជាយុទ្ធសាស្ត្រសម្រាប់ស្ត្រី និងស្វែងយល់មើលថាតើគម្រោងទំនប់អាចបង្កអន្តរាយដូចម្តេចខ្លះទៅលើសមត្ថភាពស្ត្រីក្នុងការសម្រេចបាននូវតម្រូវការនិងផលប្រយោជន៍របស់ពួកគាត់។ ការវាយតម្លៃនេះអាចធានាថាស្ថាប័នបានគិតគូរពីតម្រូវការនិងផលប្រយោជន៍ស្ត្រីនៅពេលធ្វើផែនការនិងអនុវត្តយុទ្ធនាការ ដូចជា ការគាំទ្រឱ្យស្ត្រីចូលរួមនិងដឹកនាំយុទ្ធនាការតាមរយៈការផ្តល់ឱកាសដឹកនាំ ឬឱកាសបណ្តុះបណ្តាល។

## ជំហានទី៦៖ ស្វែងយល់ពីផលប៉ះពាល់នៃគម្រោងទំនប់ដែលបានស្នើដែលអាចកើតមាននៅលើស្ត្រីនិងបុរស

ជំហាននេះជាការបំពេញបន្ថែមទៅលើជំហានទាំង៥ខាងលើ ដោយសិក្សាមើលថា តើគម្រោងទំនប់អាចប៉ះពាល់ដល់ស្ត្រីដូចម្តេច និងប៉ះពាល់ដល់បុរសដូចម្តេច។ ជាពិសេស ជំហាននេះពិចារណាអំពីផលប៉ះពាល់ទៅលើ ការផ្តល់តម្លៃផ្សេងៗគ្នាទៅលើទន្លេ ពីសំណាក់ស្ត្រីនិងបុរស ការងាររបស់ស្ត្រីនិងបុរស ធនធានដែលស្ត្រីនិងបុរសប្រើប្រាស់ ភាពជាអ្នកដឹកនាំ និងការចូលរួមរបស់ស្ត្រីក្នុងការសម្រេចចិត្ត និងតម្រូវការនិងផលប្រយោជន៍របស់ស្ត្រី។ ជំហាននេះស្វែងយល់លម្អិតអំពីផលប៉ះពាល់យេនឌ័រដោយសារគម្រោងទំនប់។ លទ្ធផលនៃការវិភាគនេះអាចប្រើសម្រាប់រៀបចំផែនការយុទ្ធនាការដែលគិតគូរដល់យេនឌ័រ ដោយធានាថា ផលប៉ះពាល់អវិជ្ជមានរបស់ទំនប់ទៅលើស្ត្រីគឺជាបញ្ហាអាទិភាពសម្រាប់យុទ្ធនាការ។ ការយល់ដឹងនិងការចងក្រងនូវព័ត៌មានទាំងនេះនឹងរួមចំណែកផ្តល់សិទ្ធិអំណាចបន្ថែមដល់ស្ត្រី (និងបុរសផងដែរ) នៅពេលពួកគាត់តស៊ូមតិជាមួយម្ចាស់គម្រោង ដើម្បីផលប្រយោជន៍ពួកគាត់។

## ផ្នែកទី៤

# ការរៀបចំនិងការអនុវត្តយុទ្ធនាការទំនប់និងទន្លេដែលឆ្លើយតបទៅនឹងយេនឌ័រ



ធនធានជលផល និងធនធានធម្មជាតិនៅក្នុងទន្លេមេគង្គគាំទ្រដល់ជីវភាពនិងសន្តិសុខស្បៀងរបស់ប្រជាជនជាង៦០លាននាក់ | រូបថតដោយ អង្គការទន្លេអន្តរជាតិ

ផ្នែកនេះផ្តោតលើរបៀបរៀបចំផែនការយុទ្ធនាការដែលគិតគូរដល់យេនឌ័រ និងធានាថាបានបញ្ជ្រាបយេនឌ័រនៅក្នុងការងារយុទ្ធនាការ។ ចំណុចនេះតម្រូវឱ្យស្ថាប័នប្រើប្រាស់លទ្ធផលដែលទទួលបានពីការវាយតម្លៃស្ថាប័ន ការវាយតម្លៃយុទ្ធនាការ និងការវិភាគយេនឌ័រដែលបានធ្វើជាមួយសហគមន៍។ ដូច្នេះស្ថាប័នអាចរៀបចំផែនការនិងអនុវត្តយុទ្ធនាការរបស់ខ្លួន ដើម្បីបំពេញសិទ្ធិនិងតម្រូវការរបស់ស្ត្រីនិងបុរស តាមរយៈការអនុវត្តនិងសម្រេចបាននូវគោលដៅនៃយុទ្ធនាការ។

ដូចនៅក្នុងការវិភាគយេនឌ័រដែរ ការរៀបចំយុទ្ធនាការគួរធ្វើឡើងទៅតាមគោលការណ៍មួយចំនួនដែលលើកកម្ពស់យេនឌ័រ។ យុទ្ធនាការគួរមានលក្ខណៈដូចខាងក្រោម៖

- មានការចូលរួម
- ជំរុញការចូលរួមនិងភាពជាអ្នកដឹកនាំពេញលេញរបស់ស្ត្រីក្នុងការសម្រេចចិត្តអំពីយុទ្ធនាការ
- អនុញ្ញាតឱ្យមានការរៀនសូត្រនិងការអនុវត្តសកម្មភាពរួមគ្នាជាសមូហភាព
- ផ្តោតសំខាន់លើក្រុមជនបាត់បង់ឱកាសបំផុត
- ពិចារណាអំពីកត្តាកំណត់អត្តសញ្ញាណចម្រុះរបស់មនុស្ស
- អនុលោមទៅតាមគោលការណ៍សិទ្ធិមនុស្ស
- សំដៅឆ្ពោះទៅរកការផ្លាស់ប្តូរជាវិជ្ជមាន

បញ្ជីផ្ទៀងផ្ទាត់សម្រាប់ផែនការយុទ្ធនាការ (មាននៅក្នុងឧបសម្ព័ន្ធទី១០) ត្រូវបានរៀបចំឡើងជាជំនួយដល់ស្ថាប័ន ដើម្បីធានាថាយុទ្ធនាការរបស់ខ្លួនឆ្លើយតបទៅនឹងយេនឌ័រ។ អ្នកអាចប្រើបញ្ជីនេះដើម្បីវាយតម្លៃវិសាលភាពឆ្លើយតបនឹងយេនឌ័រ និងកែលម្អផែនការ ដោយផ្តោតទៅលើបញ្ហាយេនឌ័រ។ ម៉្យាងវិញទៀត អ្នកអាចកែប្រែបញ្ជីផ្ទៀងផ្ទាត់នេះ និងប្រើប្រាស់វាជាឧបករណ៍រៀបចំផែនការក៏បាន។

វិធីសាស្ត្របញ្ជ្រាបយេនឌ័រមានគោលបំណងរៀបចំយ៉ាងណាឱ្យគោលដៅ វត្ថុបំណង សកម្មភាព និងយុទ្ធសាស្ត្ររបស់យុទ្ធនាការទំនប់និងទន្លេ ឆ្លើយតបទៅនឹងយេនឌ័រ។

## 1. គោលដៅឬវត្ថុបំណងយុទ្ធនាការ

គោលដៅឬវត្ថុបំណងគួរឆ្លុះបញ្ចាំងពីក្តីបារម្ភជាអាទិភាពរបស់ស្ត្រីនិងបុរសដែលរងគ្រោះដោយសារសំណើទំនប់ និងមានបញ្ចូលនូវលទ្ធផលនៃការវិភាគយេនឌ័រផងដែរ។ ខ្លឹមសាររបស់យុទ្ធនាការគួរមានភាពច្បាស់លាស់ ដោយបញ្ជាក់ថា យុទ្ធនាការនេះតស៊ូមតិដើម្បីលើកកម្ពស់សិទ្ធិនិងផលប្រយោជន៍របស់ស្ត្រីនិងបុរស ទប់ទល់ជាមួយនឹងសំណើសាងសង់ទំនប់។ សូមប្រយ័ត្នអំពីការសន្មតរបស់អ្នក។ បុរសនិងស្ត្រី អាចបារម្ភអំពីហានិភ័យផ្សេងគ្នា និងផ្តល់អាទិភាពលើផលប្រយោជន៍និងឱកាសផ្សេងគ្នាដែរ។

## 2. សកម្មភាពនិងយុទ្ធសាស្ត្រយុទ្ធនាការ

សកម្មភាពនិងយុទ្ធសាស្ត្រយុទ្ធនាការគួរឆ្លុះបញ្ចាំងពីក្តីបារម្ភជាអាទិភាពរបស់ស្ត្រីនិងបុរស និង៖

a. លើកកម្ពស់ភាពជាអ្នកដឹកនាំ សំឡេង និងសកម្មភាពរបស់ស្ត្រីនៅក្នុងយុទ្ធនាការ
b. កំណត់យុទ្ធសាស្ត្រច្បាស់លាស់ក្នុងគោលបំណងជម្នះឧបសគ្គរារាំងការចូលរួមរបស់ស្ត្រីក្នុងយុទ្ធនាការ
c. ធានាថា សកម្មភាពយុទ្ធនាការអនុញ្ញាតឱ្យទាំងស្ត្រីនិងបុរសចូលរួម (និងពិចារណាអំពីពេលវេលា និងទីកន្លែងដែលមិនបង្កជាឧបសគ្គដល់ការចូលរួមរបស់ស្ត្រី)
d. គាំទ្រការចូលរួមរបស់ស្ត្រីតាមរយៈការកសាងសមត្ថភាពនិងឱកាសនានាដើម្បីកសាងទំនុកចិត្ត ជំនាញ និងបណ្តាញទំនាក់ទំនង
e. ផ្តល់អាទិភាពដល់ការចូលរួមរបស់ស្ត្រី ឱ្យបានស្មើភាពនិងជាផ្លូវការ នៅក្នុងការពិគ្រោះយោបល់ និងសម្រេចចិត្ត ជាមួយម្ចាស់គម្រោងនិងរដ្ឋាភិបាល នៅក្នុងការប្រជុំបណ្តាញសង្គមស៊ីវិល និងការកសាងសមត្ថភាពពាក់ព័ន្ធនឹងយុទ្ធនាការ
f. សហការជាដៃគូជាមួយអង្គការសិទ្ធិស្ត្រី

វិធីសាស្ត្របញ្ជ្រាបយេនឌ័រចាំបាច់ត្រូវកំណត់ថវិកាដោយឡែក សម្រាប់គាំទ្រដល់ការចូលរួមរបស់ស្ត្រីក្នុងយុទ្ធនាការ ដូចជាថវិកាសម្រាប់៖

- ថ្លៃធ្វើដំណើរដើម្បីឱ្យស្ត្រីអាចចូលរួមសកម្មភាពយុទ្ធនាការ
- កន្លែងថែទាំកុមារដើម្បីឱ្យស្ត្រីអាចចូលរួមក្នុងសកម្មភាពនានា
- ការបណ្តុះបណ្តាលពង្រឹងចំណេះដឹងបច្ចេកទេសឬជំនាញនិយាយជាសាធារណៈសម្រាប់ស្ត្រី
- ប្រាក់សំណងដើម្បីទូទាត់ដល់ការដែលពួកគាត់ខាតបង់ពេលវេលារកប្រាក់ចំណូល
- រៀបចំឱ្យមានអ្នកបកប្រែស្រីនិងអ្នកសម្របសម្រួលស្រី ដើម្បីលើកកម្ពស់ការចូលរួមនិងសំឡេងរបស់ស្ត្រី

# ឯកសារឧបសម្ព័ន្ធ



ទូកនេសាទនៅលើទន្លេមេគង្គ។ ទន្លេមេគង្គក្រោមរងផលប៉ះពាល់ដោយសារការអភិវឌ្ឍទំនប់វារីអគ្គិសនី នៅតាមខ្សែទឹកខាងលើនៃប្រទេសចិន និងនៅក្នុងអាងទន្លេប៉ែកខាងក្រោមនៅប្រទេសឡាវ។ | រូបថតដោយ អង្គការទន្លេអន្តរជាតិ



# ឧបសម្ព័ន្ធទី១៖ និយមន័យពាក្យគន្លឹះអំពីយេនឌ័រ

និយមន័យទាំងនេះត្រូវបានប្រែសម្រួលចេញពីប្រភពផ្សេងៗ រួមទាំងសទ្ទានុក្រមសមធម៌យេនឌ័ររបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលស្ត្រីនៃអង្គការសហប្រជាជាតិផងដែរ។

## យេនឌ័រ

យេនឌ័រមិនសំដៅទៅលើភេទទេ ប៉ុន្តែវាសំដៅដល់បទពិសោធន៍ក្នុងនាមជាបុរសឬជាស្ត្រី និងទស្សនៈដែលសង្គមយល់ឃើញចំពោះតួនាទីនិងទំនួលខុសត្រូវរបស់បុរសនិងស្ត្រី។ ទស្សនៈយល់ឃើញនេះបង្កឱ្យមានការបែងចែករវាង ស្ត្រី និង បុរស ហើយសន្មតថាភេទនីមួយៗគួរមានការការគិត ឥរិយាបថ និងកាប្រព្រឹត្តទៅតាមបែបបទរៀងខ្លួន។ ទស្សនៈនេះក៏កំណត់នូវរបៀបក្នុងការរៀបចំផ្ទត់សង្គមផងដែរ។ ការបែងចែកយេនឌ័របែបនេះបណ្តាលឱ្យសង្គមកំណត់តម្លៃទៅលើ បុរស ស្ត្រី ក្មេងស្រី និង ក្មេងប្រុស ខុសៗគ្នា និងបែងចែកតួនាទីនិងទំនួលខុសត្រូវទៅតាមនោះ។

សង្គមកំណត់បែងចែកតួនាទីទៅឱ្យមនុស្សដោយផ្អែកទៅតាមយេនឌ័រផ្សេងៗគ្នា។ តម្លៃរបស់តួនាទីទាបឬខ្ពស់ ជះឥទ្ធិពលលើលទ្ធភាពក្នុងការទទួលបានផលប្រយោជន៍ ការគ្រប់គ្រង និងឥទ្ធិពលក្នុងការសម្រេចចិត្ត។ ការកំណត់តួនាទីទៅតាមយេនឌ័របែបនេះអាចបង្កឱ្យមានបញ្ហានិងការរើសអើងកាន់តែធ្ងន់ធ្ងរជាពិសេសក្នុងករណីដែលមនុស្សមិនកំណត់ខ្លួនឯងទៅតាមអត្តសញ្ញាណភេទណាមួយ ដូចជាអ្នកកែភេទ អ្នកមានសរីរាង្គភេទមិនប្រុសឬមិនស្រីពីកំណើត និងអ្នកដែលគ្មានចំណូលផ្លូវភេទ ជាដើម។

## ភេទ

ភេទសំដៅដល់លក្ខណៈជីវសាស្ត្រនិងរូបសាស្ត្រពីធម្មជាតិរវាងបុរសនិងស្ត្រី។ ប៉ុន្តែភេទមិនកំណត់ត្រឹមតែជាមួយនឹងអ្វីដែលមនុស្សកើតមកជាមួយ ដោយផ្អែកទៅលើក្រូម៉ូសូមY និងX នោះទេ។ បើយើងក្រឡេកមើលតែនៅក្នុងដែនកំណត់នៃទ្វេភេទ(ប្រុស/ស្រី) យើងមិនអាចយល់ច្បាស់អំពីមនុស្សដែលមានអត្តសញ្ញាណផ្សេងទៀតឡើយ ដូចជា អ្នកផ្លាស់ប្តូរយេនឌ័រ អ្នកមានសរីរាង្គភេទមិនប្រុសមិនស្រីពីកំណើត និងអ្នកដែលគ្មានចំណូលផ្លូវភេទ ជាដើម។ យើងអាចយល់ពីពួកគាត់បានលុះត្រាយើងពិចារណាថា ឥរិយាបថភេទមានវិសាលភាពចម្រុះ។

## ការទទួលបាននិងការគ្រប់គ្រងធនធាន

ការទទួលបានសំដៅដល់ឱកាសទទួលបានធនធានដើម្បីប្រើប្រាស់ ចំណែកការគ្រប់គ្រងសំដៅដល់ឥទ្ធិពលក្នុងការសម្រេចចិត្តលើការប្រើប្រាស់ធនធាន និងសិទ្ធិអំណាចក្នុងចាត់ចែងថានរណាអាចប្រើប្រាស់ធនធាននោះបាន។

## ទំនាក់ទំនងយេនឌ័រ

សំដៅដល់ទំនាក់ទំនងសង្គមរវាងបុរសនិងស្ត្រី ក្នុងរយៈពេលនិងទីកន្លែងជាក់លាក់។ ទំនាក់ទំនងសង្គមកំណត់នូវកម្រិតឥទ្ធិពលខុសគ្នាក្នុងចំណោមភេទទាំងពីរ។ ស្ត្រីទាំងអស់ ឬបុរសទាំងអស់មិនដូចគ្នាទេ។ ទំនាក់ទំនងយេនឌ័រផ្សារភ្ជាប់និងមានដំណើរប្រទាក់ប្រទងគ្នាជាមួយនឹងអត្តសញ្ញាណសង្គមដទៃទៀត ដូចជា សាសនា និន្នាការនយោបាយ ជនជាតិ ឋានៈក្នុងសង្គម អាយុ និងចំណូលផ្លូវភេទ។

## ផ្នត់ទស្សនៈអំពីយេនឌ័រ

ផ្នត់ទស្សនៈយេនឌ័រគឺជាសំណុំនៃជំនឿឬការគិតដែលកំណត់ទុកជាមុននូវលក្ខណៈ ការប្រព្រឹត្ត តួនាទី និងការរំពឹងទុកសម្រាប់បុរសនិងស្ត្រី។ ផ្នត់ទស្សនៈទាំងនេះគឺជាការយល់ឃើញបែបលំអៀង ហើយច្រើនតែក្នុងរូបភាពបំផ្លើសទៅលើស្ត្រីនិងបុរស ហើយគេតែងប្រើវាជាគោលគំនិតជាប្រចាំ។

## សមធម៌យេនឌ័រ

គឺជាភាពយុត្តិធម៌ចំពោះស្ត្រីនិងបុរស។ ដើម្បីធានាបាននូវភាពយុត្តិធម៌ ចាំបាច់ត្រូវមានវិធានការណ៍ដើម្បីទប់ទល់ជាមួយនឹងគុណវិបត្តិសង្គមនិងទម្លាប់ពីអតីតកាលដែលជាឧបសគ្គរារាំងមិនឱ្យស្ត្រីនិងបុរសទទួលបាននូវស្ថានភាពយុត្តិធម៌។

## សមភាពយេនឌ័រ

សំដៅដល់អវត្តមាននៃការរើសអើងទៅលើភេទរបស់បុគ្គលពាក់ព័ន្ធនឹងការទទួលបានសិទ្ធិអំណាច ឱកាស ការបែងចែកធនធានឬផលប្រយោជន៍ និងការទទួលបានសេវាកម្ម។ សមភាពយេនឌ័រគឺជាការឱ្យតម្លៃស្មើគ្នាពីសំណាក់សង្គម ទៅលើភាពដូចគ្នានិងភាពខុសគ្នារវាងបុរសនិងស្ត្រី និងតួនាទីរបស់ពួកគាត់។ បញ្ហាយេនឌ័រកើតមានឡើងនៅពេលមានវិសមភាព អសមធម៌ ឬការប្រព្រឹត្តមិនស្មើគ្នាទៅលើបុគ្គលឬក្រុម ដោយសារការរំពឹងរបស់សង្គមនិងលក្ខណៈយេនឌ័រ។

## ការវិភាគយេនឌ័រ

គឺជាដំណើរការនៃការពិនិត្យមើលទៅលើ តួនាទីនិងទំនួលខុសត្រូវរបស់ស្ត្រីនិងបុរស ទំនាក់ទំនងរវាងស្ត្រីនិងបុរស និងវិសមភាពនៅក្នុងទំនាក់ទំនង។ ការវិភាគយេនឌ័រពិនិត្យមើលទំនាក់ទំនងឥទ្ធិពលនៅក្នុងគ្រួសារ ក្នុងស្ថាប័ន និងក្នុងសង្គម និងលើកកម្ពស់សមភាពយេនឌ័រ។

## ការចេះគិតគូរពីយេនឌ័រ

មានគោលបំណងស្វែងយល់និងពិចារណាទៅលើកត្តាសង្គមនិងវប្បធម៌ដែលបដិសេធនិងរើសអើងយេនឌ័រ។

## ការឆ្លើយតបផ្នែកយេនឌ័រ

សំដៅទៅលើការធ្វើផែនការនិងការអនុវត្តសកម្មភាពកម្មវិធីដែលឆ្លើយតបនឹងបញ្ហាយេនឌ័រ និងលើកកម្ពស់សមភាពយេនឌ័រ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍ដែលគិតគូរអំពីយេនឌ័រនៅក្នុងការអនុវត្តការងារ។

## បម្រែបម្រួលយេនឌ័រ

យេនឌ័រត្រូវបានចាត់ទុកជាកត្តាសំខាន់ក្នុងការលើកកម្ពស់សមភាព និងផ្លាស់ប្តូរពីឥទ្ធិពលមិនស្មើគ្នាទៅជា ការលើកកម្ពស់ឥទ្ធិពលរួម ការគ្រប់គ្រងធនធានរួម ការសម្រេចចិត្តរួម និងការលើកកម្ពស់សិទ្ធិអំណាចស្ត្រី។

## ការបញ្ជ្រាបយេនឌ័រ

សំដៅដល់ដំណើរការនៃការបញ្ជ្រាបទស្សនៈស្តីពីសមភាពយេនឌ័រទៅក្នុងដំណើរការអភិវឌ្ឍនៅគ្រប់ដំណាក់កាលនិងគ្រប់កម្រិត។ ការបញ្ជ្រាបយេនឌ័រគឺជាយុទ្ធសាស្ត្រមួយដើម្បីសម្រេចបាននូវសមភាពយេនឌ័រ។

## ការវាយតម្លៃផលប៉ះពាល់យេនឌ័រ

គេច្រើនធ្វើការវាយតម្លៃផលប៉ះពាល់យេនឌ័រដើម្បីសិក្សាផែនការគម្រោង (មុនពេលមានគម្រោង) ដោយស្វែងរកមើលផលប៉ះពាល់ទាក់ទងនឹងយេនឌ័រ។ គេវាយតម្លៃអំពីផលប៉ះពាល់របស់គម្រោងទៅលើបុរសនិងស្ត្រីនិងទំនាក់ទំនងយេនឌ័រជាទូទៅ។ ការវាយតម្លៃផលប៉ះពាល់យេនឌ័រធ្វើការប្រៀបធៀបស្ថានភាពនិងនិន្នាការបច្ចុប្បន្ន ជាមួយនឹងលទ្ធផលរំពឹងទុករបស់គម្រោងដោយផ្អែកលើលក្ខខណ្ឌយេនឌ័រពាក់ព័ន្ធ។ វាគឺជាឧបករណ៍ដ៏មានប្រយោជន៍ដើម្បីការពារមិនឱ្យគម្រោងមានភាពលំអៀងផ្នែកយេនឌ័រ ឬមើលរំលងយេនឌ័រ។ គេគួរវាយតម្លៃផលប៉ះពាល់យេនឌ័រមុនពេលធ្វើការសម្រេចចិត្តចុងក្រោយទៅលើសំណើគម្រោង ដើម្បីធានាថា គម្រោងនោះគាំទ្រសមភាពយេនឌ័រ និងមិនបន្តពង្រីកវិសមភាពដែលមានស្រាប់ទេ។ ការវាយតម្លៃនេះអាចប្រើប្រាស់ដើម្បីពិនិត្យឡើងវិញ និងកែតម្រូវផែនការគម្រោងផងដែរ។

## ការលើកកម្ពស់សិទ្ធិអំណាចស្ត្រី

ការលើកកម្ពស់សិទ្ធិអំណាចស្ត្រីមានទំនាក់ទំនងជាមួយនឹងបម្រែបម្រួលយេនឌ័រ។ វាគឺជាដំណើរការនៃការដោះស្រាយនិងផ្លាស់ប្តូរឥទ្ធិពលរវាងបុរសនិងស្ត្រី។ គេអាចសម្រេចបាននូវការលើកកម្ពស់សិទ្ធិអំណាចស្ត្រីជាបុគ្គល ឬជាក្រុម នៅពេលមានការផ្លាស់ប្តូរទៅលើឧបសគ្គនិងឱកាសសម្រាប់ស្ត្រី និងការសម្រេចបាននូវសិទ្ធិស្ត្រី។

## កត្តាប្រសព្វ

គឺជាការយល់ដឹងអំពីយេនឌ័រ រួមជាមួយនឹងកត្តាសង្គមផ្សេងទៀត។ ដើម្បីយល់ឱ្យបានពេញលេញអំពីឥទ្ធិពលនិងភាពងាយរងគ្រោះ ចាំបាច់ត្រូវក្រឡេកមើលទៅលើយេនឌ័រ រួមជាមួយនឹងកត្តាពាក់ព័ន្ធដទៃទៀត ដូចជា ឋានៈ ការអប់រំ សញ្ជាតិ ពូជសាសន៍ ពណ៌សម្បុរ និងពិការភាព។

## តម្រូវការយេនឌ័រជាក់ស្តែង

តម្រូវការយេនឌ័រជាក់ស្តែងគឺជាតម្រូវការដែលកើតឡើងពីស្ថានភាពជាក់ស្តែងដែលស្ត្រីជួបប្រទះ ដោយសារតែតួនាទីដែលសង្គមបានកំណត់ឱ្យពួកគាត់។ តម្រូវការទាំងនេះច្រើនតែពាក់ព័ន្ធទៅនឹងតួនាទីរបស់ស្ត្រីជាម្តាយ ជាមេផ្ទះ និងជាអ្នកផ្តល់នូវតម្រូវការមូលដ្ឋាន ដោយផ្សារភ្ជាប់ជាមួយនឹងកង្វះខាតជីវភាពដូចជា ស្បៀងអាហារ ទីជំរក ប្រាក់ចំណូល ការអប់រំរបស់កូន ទឹកប្រើប្រាស់ សុខភាព និងការងារ។ ការបំពេញតម្រូវការជាក់ស្តែងទាំងនេះនឹងមិនផ្លាស់ប្តូរមូលហេតុដែលបង្កឱ្យស្ត្រីក្លាយជាក្រុមដែលបាត់បង់ឱកាសនៅក្នុងសង្គមឡើយ។

## ផលប្រយោជន៍យេនឌ័រជាយុទ្ធសាស្ត្រ

ផលប្រយោជន៍យេនឌ័រជាយុទ្ធសាស្ត្រគឺជាអ្វីដែលយើងត្រូវការដើម្បីជម្នះស្ថានភាពទាបរបស់ស្ត្រីធៀបនឹងបុរស នៅក្នុងសង្គម និងផ្តល់សិទ្ធិអំណាចដល់ស្ត្រី។ ផលប្រយោជន៍ទាំងនេះអាចខុសគ្នាទៅតាមបរិបទសង្គម សេដ្ឋកិច្ច និងនយោបាយ។ ជាធម្មតា វាពាក់ព័ន្ធជាមួយបញ្ហាសមភាពដូចជា ការផ្តល់លទ្ធភាពឱ្យស្ត្រីទទួលបានឱកាសការងារ ការបណ្តុះបណ្តាល ប្រាក់ឈ្នួលស្មើគ្នាសម្រាប់ការងារមានតម្លៃដូចគ្នា កម្មសិទ្ធិដីធ្លីនិងទ្រព្យសម្បត្តិ ការទប់ស្កាត់ការបៀតបៀនផ្លូវភេទនិងហិង្សាលើស្ត្រី និងសេរីភាពក្នុងការសម្រេចអំពីការមានឬគ្មានកូន។

## តួនាទីផលិតភាព

សំដៅដល់ការងារដែលបុរសឬស្ត្រីធ្វើ ហើយទទួលបានលទ្ធផលមកវិញជាប្រាក់ឬជាភោគផលមិនមែនប្រាក់ ឧទាហរណ៍ ផលិតកម្មឬសេវាកម្មលើទីផ្សារដែលអាចប្តូរបានជាកម្រៃ និងផលិតកម្មតាមផ្ទះសម្រាប់ប្រើប្រាស់ចិញ្ចឹមជីវិតឬអាចមានសក្តានុពលប្តូរបានជាកម្រៃ។ តួនាទីផលិតភាពរបស់ស្ត្រីនៅក្នុងផលិតកម្មកសិកម្មមានដូចជា ម្ចាស់ស្រែចំការ កសិករ និងកម្មករ។

## តួនាទីពាក់ព័ន្ធនឹងការបន្តពូជ

សំដៅដល់ការបង្កើតចិញ្ចឹមបីបាច់កូន និងកិច្ចការនានាដែលត្រូវបំពេញក្នុងគោលបំណងថែទាំដល់សមាជិកគ្រួសារ និងសហគមន៍។ តួនាទីនេះមានដូចជា ការងារនៅផ្ទះដែលស្ត្រីធ្វើដើម្បីថែទាំនិងកសាងធនធានកម្លាំងពលកម្ម ដូចជា ផ្តល់កំណើតកូន ធ្វើម្ហូប រើសអុស ដងទឹក មើលកូន អប់រំណែនាំ និងថែទាំសុខភាពសមាជិកគ្រួសារ។

## តួនាទីគ្រប់គ្រងសហគមន៍

សកម្មភាពដែលស្ត្រីធ្វើនៅក្នុងសហគមន៍ បន្ថែមពីលើកិច្ចការផ្ទះរបស់ខ្លួន ពាក់ព័ន្ធនឹងការផ្តល់និងការថែរក្សាធនធានប្រើប្រាស់សមូហភាពដូចជា ទឹកប្រើប្រាស់ សុខភាព និងការអប់រំ ហើយជាធម្មតា វាជាការងារស្ម័គ្រចិត្ត និងគ្មានប្រាក់កម្រៃ។

## តួនាទីនយោបាយសហគមន៍

សកម្មភាពដែលបុរសធ្វើនៅក្នុងសហគមន៍ ដូចជាការរៀបចំកិច្ចការពាក់ព័ន្ធនឹងនយោបាយ ស្របទៅតាមក្របខ័ណ្ឌនយោបាយជាតិ ហើយវាជាការងារដែលទទួលបានប្រាក់កម្រៃដោយផ្ទាល់ឬដោយប្រយោលតាមរយៈឋានៈឬឥទ្ធិពល។

## ការងារថែទាំគ្មានប្រាក់កម្រៃ

ការងារថែទាំគ្មានប្រាក់កម្រៃសំដៅដល់កិច្ចការផ្ទះគ្រប់ទម្រង់ដូចជា ចម្អិនម្ហូប បោសជូត បោកខោអាវ លាងសំអាត ថែសួនដំណាំ មើលផ្ទះ និងមើលថែទាំកុមារ មនុស្សចាស់ ឬសមាជិកគ្រួសារឈឺឬពិការ។ កិច្ចការនេះគ្មានប្រាក់កម្រៃទេ ហើយជាធម្មតា ស្ត្រី(និងក្មេងស្រី)ចំណាយពេលវេលាច្រើនធ្វើកិច្ចការទាំងនេះ ក្នុងកម្រិតមិនសមាមាត្រ ធៀបជាមួយនឹងបុរស។

# ឧបសម្ព័ន្ធទី២៖ ការវាយតម្លៃយេនឌ័រសម្រាប់ស្ថាប័ន

ការវាយតម្លៃយេនឌ័រសម្រាប់ស្ថាប័នមានបំណងជួយឱ្យស្ថាប័នឆ្លុះបញ្ចាំងនិងកែលម្អការអនុវត្តយេនឌ័ររបស់ខ្លួននៅក្នុងស្ថាប័ន។ ការវាយតម្លៃនេះគួរធ្វើឡើងដោយមានការចូលរួមពីសំណាក់បុគ្គលិកនិងដៃគូទាំងអស់ ដើម្បីឱ្យមានការយល់ដឹងរួមគ្នាអំពីការអនុវត្តយេនឌ័រ និងការប្តេជ្ញាចិត្តរួមក្នុងការដោះស្រាយនូវចំណុចខ្វះខាត និងកែលម្អការអនុវត្ត។

គួរចំណាយពេលវេលាឱ្យបានច្រើនសម្រាប់ការវាយតម្លៃនេះ (តិចបំផុត ២ឬ៣ម៉ោង) ដើម្បីមានពេលវេលាគ្រប់គ្រាន់ពិចារណាលើទស្សនៈយោបល់របស់សមាជិកគ្រប់គ្នានៅក្នុងស្ថាប័ន និងមូលមតិព្រមព្រៀងគ្នាលើសកម្មភាពឆ្លើយតប។ មិនគួរធ្វើការវាយតម្លៃដូចជាលក្ខណៈលំហាត់ផ្ទៀងផ្ទាត់ដើម្បីគូសចម្លើយនោះទេ គួរជាការឆ្លុះបញ្ចាំង ពិភាក្សា និងការប្តេជ្ញាចិត្តធ្វើសកម្មភាពដែលប្រកបដោយអត្ថន័យនិងការចូលរួម។

នៅទំព័របន្ទាប់គឺជាសំណួរសម្រាប់ជាជំនួយក្នុងការឆ្លុះបញ្ចាំង។ អ្នកអាចបន្ថែមសំណួរផ្សេងទៀត ឬក្រឡោនបន្ថែមទៀតទៅក្នុងតារាងខាងក្រោមផងដែរ ឧទាហរណ៍ក្រឡោនអំពីស្ថានភាពការងារបច្ចុប្បន្នដែលពាក់ព័ន្ធនឹងសំណួរនីមួយៗ។ អ្នកអាចប្រើតារាងខាងក្រោមដើម្បីកត់ត្រាលទ្ធផលនៃការវាយតម្លៃ និងបង្កើតជាមូលដ្ឋានសម្រាប់ផែនការសកម្មភាពយេនឌ័រដើម្បីតាមដានលើវឌ្ឍនភាពការអនុវត្តយេនឌ័រ។

គួរប្រើលទ្ធផលនៃការវាយតម្លៃនេះដើម្បីសិក្សាមើលអំពី កង្វះខាតក្នុងការអនុវត្តយេនឌ័របានល្អ និងរៀបចំសកម្មភាពអាទិភាពដើម្បីបំពេញកង្វះចន្លោះទាំងនេះ និងកែលម្អការអនុវត្តយេនឌ័រឱ្យបានប្រសើរឡើង។

## ជំហានបន្ទាប់៖

- ប្រើការវាយតម្លៃនេះដើម្បីផ្តួចផ្តើមការជជែកវែកញែកបន្ថែមទៀតអំពីការអនុវត្តយេនឌ័ររបស់ស្ថាប័ននិងកង្វះចន្លោះក្នុងការអនុវត្ត។
- រៀបចំផែនការសកម្មភាពយេនឌ័រ និងព្រមព្រៀងលើសកម្មភាពអាទិភាពដើម្បីដោះស្រាយកង្វះចន្លោះទាំងនោះ។
- ចាត់ចែងថវិកាមួយចំនួនសម្រាប់ដោះស្រាយកង្វះចន្លោះអាទិភាព។
- តាមដានវឌ្ឍនភាពនៃការអនុវត្តសកម្មភាពដែលបានព្រមព្រៀង។
- វាយតម្លៃជាប្រចាំ (ឧ. រៀងរាល់ឆ្នាំ) ដើម្បីឱ្យបុគ្គលិកអាចឆ្លុះបញ្ចាំងនិងពិភាក្សាអំពីវឌ្ឍនភាពតាំងពីពេលវាយតម្លៃលើកមុន និងប្តេជ្ញាចិត្តចំពោះសកម្មភាពបន្តទៅមុខទៀត។
- គួរគិតគូរផ្តល់ការបណ្តុះបណ្តាលនិងការអភិវឌ្ឍវិជ្ជាជីវៈអំពីយេនឌ័រដល់បុគ្គលិកទាំងអស់។

## ឧបករណ៍វាយតម្លៃយេនឌ័រសម្រាប់ស្ថាប័ន

INTERNATIONAL RIVERS
PEOPLE · WATER · LIFE

| សំណួរគន្លឹះ | បាស/បាទឬទេ | បើពិត សូមពណ៌នាឬពន្យល់បន្ថែម បើទេ សូមបញ្ជាក់ពីដំណោះស្រាយ |
|---|---|---|
| **គោលនយោបាយ** | | |
| តើមានគោលនយោបាយច្បាស់លាស់ដែលបង្ហាញពីការប្តេជ្ញាចិត្តចំពោះសមភាពយេនឌ័រនិងការមិនរើសអើងឬទេ (ដូចជា ស្ថានភាពភេទ ការមានផ្ទៃពោះ និងទំនួលខុសត្រូវគ្រួសារ ជាដើម)? | | |
| តើមានគោលនយោបាយច្បាស់លាស់ដែលបង្ហាញពីការប្តេជ្ញាចិត្តចំពោះការបញ្ជ្រាបយេនឌ័រនិងការផ្តល់អាទិភាពដល់តម្រូវការនិងផលប្រយោជន៍របស់ស្រ្តី នៅក្នុងការងាររបស់ខ្លួនដែរឬទេ? | | |
| **ធនធានមនុស្ស** | | |
| តើមានធនធានមនុស្ស (ឧ. អ្នកឯកទេសយេនឌ័រ) និងធនធាននានា ដើម្បីជួយកសាងសមត្ថភាពយេនឌ័របុគ្គលិកដែរឬទេ? | | |
| តើស្ថាប័នមានក្រុមការងារយេនឌ័រ ឬក្រុមស្រដៀងនេះ ដើម្បីសម្រួលដល់ការរៀនសូត្រអំពីយេនឌ័រឬទេ? | | |
| តើស្ថាប័នបានជ្រើសរើសបុគ្គលិកដោយផ្អែកលើចំណេះដឹង ជំនាញ និងឥរិយាបថអំពីយេនឌ័រដែរឬទេ? | | |
| តើមានតុល្យភាពចំនួនបុគ្គលិកស្រីនិងប្រុសនៅក្នុងស្ថាប័ន និងនៅក្នុងតំណែងសម្រេចចិត្តជាន់ខ្ពស់ដែរឬទេ? | | |
| **ការអនុវត្តៈ ធនធាននិងចំណេះដឹង** | | |
| តើការវិភាគយេនឌ័រផ្តល់ព័ត៌មានជាទុនក្នុងការធ្វើផែនការគម្រោងអនុវត្ត និងតាមដានត្រួតពិនិត្យដែរឬទេ? | | |
| តើបុគ្គលិកមានចំណេះដឹង ជំនាញ និងឥរិយាបថយេនឌ័រសមស្របទេ? | | |
| តើបុគ្គលិកអាចទទួលបានការបណ្តុះបណ្តាលដើម្បីបង្កើនសមត្ថភាពយេនឌ័ររបស់ពួកគេដែរឬទេ? | | |
| តើបុគ្គលិកទាំងអស់ត្រូវបានតម្រូវឱ្យចូលរួមការបណ្តុះបណ្តាលយេនឌ័រដែរឬទេ? | | |
| តើមានបម្រុងធនធានហិរញ្ញវត្ថុដើម្បីគាំទ្រការអនុវត្តយេនឌ័រទេ? | | |
| តើមានឧបករណ៍ ការណែនាំ ទម្រង់ផែនការ ជាដើម ជាជំនួយដល់បុគ្គលិកដើម្បីអនុវត្តយេនឌ័រនៅក្នុងការងារពួកគេដែរឬទេ? | | |
| តើដៃគូទទួលបានការគាំទ្រដើម្បីបង្កើនចំណេះដឹង ជំនាញ និងឥរិយាបទយេនឌ័រដែរឬទេ? | | |

# ឧបសម្ព័ន្ធទី៣៖ វាយតម្លៃយេនឌ័រសម្រាប់យុទ្ធនាការ

ការវាយតម្លៃយេនឌ័រសម្រាប់យុទ្ធនាការគឺជាជំនួយដល់អង្គភាពនានាឱ្យឆ្លុះបញ្ចាំងពីការអនុវត្តយេនឌ័ររបស់ខ្លួន ជាពិសេសការបញ្ជ្រាបយេនឌ័រក្នុងការរៀបចំផែនការ និងការអនុវត្តយុទ្ធនាការទំនប់ដែលមានស្រាប់។ ការវាយតម្លៃនេះគួរធ្វើឡើងដោយមានការចូលរួមពីសំណាក់បុគ្គលិក ដៃគូទាំងអស់ និងស្ត្រីនិងបុរសនៅក្នុងសហគមន៍ ដើម្បីឱ្យមានការយល់ដឹងរួមគ្នាអំពីការអនុវត្តយេនឌ័រ និងការប្តេជ្ញាចិត្តរួមក្នុងការដោះស្រាយនូវចំណុចខ្វះខាត និងកែលម្អការអនុវត្តដោយផ្អែកលើបទពិសោធន៍និងទស្សនៈរបស់ស្ត្រីនិងបុរសដែលស្ថាប័នធ្វើការជាមួយ។

គួរចំណាយពេលវេលាឱ្យបានច្រើនសម្រាប់ការវាយតម្លៃនេះ (តិចបំផុត ២ឬ៣ម៉ោង) ដើម្បីមានពេលវេលាគ្រប់គ្រាន់ពិចារណាលើទស្សនៈយោបល់របស់ភាគីពាក់ព័ន្ធនៅក្នុងយុទ្ធនាការ និងមូលមតិព្រមព្រៀងគ្នាលើសកម្មភាពឆ្លើយតប។ មិនគួរធ្វើការវាយតម្លៃដូចជាលក្ខណៈលំហាត់ផ្ទៀងផ្ទាត់ដើម្បីគូសចម្លើយនោះទេ គួរជាការឆ្លុះបញ្ចាំង ពិភាក្សា និងការប្តេជ្ញាចិត្តធ្វើសកម្មភាពដែលប្រកបដោយអត្ថន័យ និងការចូលរួម។

នៅទំព័របន្ទាប់គឺជាសំណួរសម្រាប់ជាជំនួយក្នុងការឆ្លុះបញ្ចាំង។ អ្នកអាចបន្ថែមសំណួរផ្សេងទៀត ឬក្រឡោនបន្ថែមទៀតទៅក្នុងតារាងដើម្បីកត់ត្រាព័ត៌មានបន្ថែមសម្រាប់សំណួរនីមួយៗ។ អ្នកអាចប្រើតារាងខាងក្រោមដើម្បីកត់ត្រាលទ្ធផលនៃការវាយតម្លៃ និងសម្រាប់បង្កើតជាមូលដ្ឋានមួយសម្រាប់បញ្ជ្រាបយេនឌ័រទៅក្នុងការធ្វើផែនការ និងអនុវត្តយុទ្ធនាការ។

## ជំហានបន្ទាប់៖

- ប្រើការវាយតម្លៃនេះដើម្បីផ្តួចផ្តើមការជជែកវែកញែកបន្ថែមទៀតអំពីការអនុវត្តយេនឌ័ររបស់ស្ថាប័ននិងកង្វះចន្លោះក្នុងការអនុវត្ត។
- រៀបចំផែនការបញ្ជ្រាបយេនឌ័រឱ្យកាន់តែប្រសើរនៅក្នុងការរៀបចំនិងការអនុវត្តយុទ្ធនាការ និងព្រមព្រៀងលើសកម្មភាពអាទិភាព។
- បង្កើតសូចនាករនិងក្របខ័ណ្ឌត្រួតពិនិត្យ ដើម្បីអនុញ្ញាតឱ្យបុគ្គលិកយុទ្ធនាការ ធ្វើការវាយតម្លៃភាពជោគជ័យនៃយុទ្ធនាការ ក្នុងការឆ្លើយតបនឹងតម្រូវការនិងផលប្រយោជន៍របស់ស្ត្រីនិងបុរស។
- បែងចែកថវិកាមួយចំនួនដើម្បីគាំទ្រសកម្មភាពអាទិភាព។
- តាមដានវឌ្ឍនភាពនៃការអនុវត្តសកម្មភាពដែលបានព្រមព្រៀង។
- គួរគិតគូរផ្តល់ការបណ្តុះបណ្តាលនិងការអភិវឌ្ឍវិជ្ជាជីវៈអំពីយេនឌ័រដល់បុគ្គលិកយុទ្ធនាការ ដៃគូ និងតំណាងសហគមន៍។

# ឧបករណ៍វាយតម្លៃយេនឌ័រសម្រាប់យុទ្ធនាការ

| សំណួរគន្លឹះ | បាស/បាទឬទេ | បើពិត សូមពណ៌នាឬពន្យល់បន្ថែម បើទេ សូមបញ្ជាក់ពីដំណោះស្រាយ |
|---|---|---|
| តើអ្នកមានវត្ថុបំណងនិងគោលដៅអ្វីខ្លះ?<br>. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .<br>. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . | | |
| **ការធ្វើផែនការ** | | |
| តើវត្ថុបំណងឆ្លើយតបនឹងតម្រូវការនិងផលប្រយោជន៍របស់ស្ត្រីនិងបុរសទេ? | | |
| តើគោលបំណងទាំងនេះឆ្លើយតបទៅនឹងតម្រូវការយេនឌ័រជាក់ស្តែង និងផលប្រយោជន៍យេនឌ័រជាយុទ្ធសាស្ត្ររបស់ស្ត្រីដែរឬទេ? | | |
| តើផែនការយុទ្ធនាការផ្អែកលើការវិភាគយេនឌ័រ និងផលប៉ះពាល់ទៅលើស្ត្រីនិងបុរសក្នុងសហគមន៍ឬទេ? | | |
| តើអ្នកធ្លាប់រៀបចំឱ្យស្ត្រីនិងបុរសមកពីសហគមន៍រងគ្រោះបានចូលរួមក្នុងការរៀបចំផែនការ វត្ថុបំណង យុទ្ធសាស្ត្រ និងសកម្មភាពសម្រាប់យុទ្ធនាការដែរឬទេ? | | |
| តើស្ត្រីអាចមានឥទ្ធិពលលើការរៀបចំវត្ថុបំណង យុទ្ធសាស្ត្រ និងសកម្មភាពសម្រាប់យុទ្ធនាការទេ? | | |
| តើផែនការយុទ្ធនាការមានមូលដ្ឋានលើការវាយតម្លៃអំពី ឧបសគ្គរារាំងការចូលរួមនិងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងយុទ្ធនាការ និងយុទ្ធសាស្ត្រដើម្បីជម្នះឧបសគ្គទាំងនេះដែរឬទេ? | | |
| **ការអនុវត្ត** | | |
| តើយុទ្ធនាការរបស់អ្នកបន្លឺសំឡេងរបស់ស្ត្រីមកពីសហគមន៍ដែលរងគ្រោះដោយសារទំនប់ដែរឬទេ? | | |
| តើសកម្មភាពយុទ្ធនាការគាំទ្រដល់ការចូលរួមនិងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងយុទ្ធនាការទេ? | | |
| តើមានការតម្រូវឱ្យមានចំនួនស្ត្រីនិងបុរសស្មើគ្នានៅក្នុង ការប្រជុំជាមួយម្ចាស់គម្រោង ការប្រជុំបណ្តាញសង្គមស៊ីវិល និងការកសាងសមត្ថភាពអំពីយុទ្ធនាការ ឬទេ? | | |
| តើថវិកាយុទ្ធនាការឆ្លុះបញ្ចាំងពីសកម្មភាពយេនឌ័រឬទេ ឧ. ការកសាងសមត្ថភាពយេនឌ័រ (សម្រាប់ស្ត្រីនិងបុរស) សកម្មភាពសម្រាប់ស្ត្រី ធនធានសម្រាប់ធ្វើដំណើរឬថៃទាំកុមារដើម្បីគាំទ្រឱ្យស្ត្រីចូលរួម? | | |

# ឧបសម្ព័ន្ធទី៤៖
# ជំហានទី១ - ស្វែងយល់ថាស្ត្រីផ្ដល់តម្លៃបែបណា ហើយបុរសផ្ដល់តម្លៃបែបណាទៅឱ្យទន្លេ

នៅក្នុងជំហាននេះ យើងសុំឱ្យស្ត្រីនិងបុរសពណ៌នាអំពីសារៈសំខាន់របស់ទន្លេនិងអាងទន្លេចំពោះពួកគាត់ និងគុណប្រយោជន៍ដែលពួកគាត់ទទួលបានពីប្រព័ន្ធអេកូឡូស៊ីរបស់ទន្លេ។ គុណប្រយោជន៍អាចមានដូចជា ប្រភពសម្រាប់ចិញ្ចឹមជីវភាព សន្តិសុខស្បៀង ទឹកបរិភោគ ទឹកងូត ទឹកសំអាត ផ្លូវដឹកជញ្ជូន និងសម្រាប់គោលបំណងវប្បធម៌និងសាសនា។

ព័ត៌មានដែលប្រមូលបានអនុញ្ញាតឱ្យសហគមន៍និងស្ថាប័នស្វែងយល់អំពីយេនឌ័រនិងគុណប្រយោជន៍របស់ទន្លេនិងផ្ដល់នូវគំនិតសម្រាប់វិភាគក្នុងជំហានទី២ និងទី៣។

គួររៀបចំការសន្ទនាដាច់ដោយឡែករវាងស្ត្រី និងបុរស។ បន្ទាប់មក នាំក្រុមទាំងពីរមកជុំគ្នាវិញ និងចែករំលែកអំពីការពិភាក្សារបស់ពួកគាត់។ ធ្វើដូច្នេះនឹងជួយបង្កើនការយល់ដឹងបានប្រសើរពីទស្សនៈម្ខាងៗ។

**១. រៀបចំផ្សាក្រាមឬផែនទីភក់** អំពីទន្លេ (បង្ហាញប្រភពទឹក ដៃទន្លេ តំបន់ទំនាបលិចទឹក តំបន់ដីសើម ពាមឬដីសណ្ដរដែលពាក់ព័ន្ធ)។ អាចធ្វើនៅលើក្រដាសផ្ទាំងធំឬនៅលើដីឬដីខ្សាច់។

**២. ការពិភាក្សាដោយមានការសម្របសម្រួល**

ប្រើផែនទីដើម្បីជំរុញការឆ្លុះបញ្ចាំងនិងពិភាក្សា អំពីគុណប្រយោជន៍ដែលស្ត្រីនិងបុរសផ្ដល់ទៅឱ្យទន្លេ។ គេអាចកែតម្រូវផែនទីឬគូសសម្គាល់ ដើម្បីបង្ហាញពីកន្លែងដែលមានសកម្មភាពឬគុណប្រយោជន៍។

សំណួរជាជំនួយដើម្បីជំរុញការពិភាក្សា៖

- តើទន្លេមានសំខាន់អ្វីខ្លះសម្រាប់ស្ត្រី និងបុរស?
- តើមានអ្វីខ្លះពាក់ព័ន្ធនឹងទន្លេ ដែលមានតែស្ត្រីទេដឹង? អ្វីខ្លះដែលមានតែបុរសទេដែលដឹង?
- រាល់ថ្ងៃ តើស្ត្រីនិងបុរសប្រើប្រាស់ទន្លេយ៉ាងដូចម្ដេច? តើការប្រើប្រាស់នេះផ្លាស់ប្ដូរយ៉ាងណាខ្លះក្នុងអំឡុងពេលបន្តបន្ទាប់ពេញមួយឆ្នាំ (ពីដើមឆ្នាំដល់ចុងឆ្នាំ)?
- តើស្ត្រីនិងបុរសទទួលបានអត្ថប្រយោជន៍អ្វីខ្លះពីការប្រើប្រាស់ទាំងនេះ?
- តើស្ត្រីនិងបុរសមានធ្វើសកម្មភាពអ្វីផ្សេងទៀតជាមួយទន្លេទេ?
- ក្នុងចំណោមសកម្មភាពទាំងនេះ តើមានអ្វីពិសេសឬសំខាន់ចំពោះស្ត្រី និងបុរសឬទេ?
- តើមានគុណប្រយោជន៍ចាំបាច់សម្រាប់ស្ត្រីនិងបុរសអ្វីខ្លះដែលអាចនឹងបាត់បង់ ប្រសិនបើគេសង់ទំនប់?

ព័ត៌មានបន្ថែមអំពីការគូសផែនទីអត្ថប្រយោជន៍ និងការវិភាគយេនឌ័រ មាននៅក្នុងទីនេះ៖

www.internationalrivers.org/transforming-power



អង្គការអុកស្វាមសម្របសម្រួលលំហាត់ផែនទីទន្លេជាមួយបុគ្គលិករដ្ឋាភិបាលនៅប្រទេសឡាវ



រូបតំណាងអំពីគុណប្រយោជន៍ និងគុណតម្លៃរបស់ទន្លេកុងហ្គូ សម្រាប់ស្ត្រីនៅសហគមន៍អ៊ីនហ្គា ធ្វើឡើងនៅក្នុងសិក្ខាសាលាមួយដែលរៀបចំឡើងដោយអង្គការទន្លេអន្តរជាតិ នៅប្រទេសកុងហ្គូ ឆ្នាំ២០១៩ | រូបថតដោយអង្គការទន្លេអន្តរជាតិ។

# ឧបសម្ព័ន្ធទី៥៖
# ជំហានទី២ - ស្វែងយល់ពីការបែងចែកយេនឌ័រក្នុងកិច្ចការពលកម្ម

ជំហាននេះប្រមូលព័ត៌មានដើម្បីស្វែងយល់ពីការបែងចែកយេនឌ័រក្នុងកិច្ចការពលកម្ម (ការងារស្ត្រី និងការងារបុរស) ដូចជា អ្នកណាធ្វើអ្វីខ្លះ រយៈពេលប៉ុន្មាន ពេលណា។ យើងចង់សំដៅដល់ទាំងការងារផលិតភាព ទាំងការងារពាក់ព័ន្ធនឹងការបន្តពូជ និងការងារសហគមន៍ (និយមន័យពាក្យទាំងនេះមាននៅក្នុងឧបសម្ព័ន្ធទី១)។

ព័ត៌មានដែលទទួលបាននឹងអនុញ្ញាតឱ្យសហគមន៍និងស្ថាប័នអាចស្វែងយល់បានកាន់តែច្បាស់ថា តើគម្រោងទំនប់អាចមានឥទ្ធិពលអ្វីខ្លះទៅលើការងារស្ត្រីនិងបុរស ឧ. កំណើនបន្ទុកលើស្ត្រីនិងបុរស ឬទេ។ ឧបករណ៍សម្រាប់ជួយវិភាគអំពីចំណុចនេះមាននៅក្នុងឧបសម្ព័ន្ធទី៩។

អ្នកអាចប្រើសំណួរនិងទម្រង់គំរូខាងក្រោម ដើម្បីជាជំនួយក្នុងការចងក្រងឯកសារ និងពិភាក្សា ជាមួយស្ត្រីនិងបុរស អំពីភារកិច្ចនិងទំនួលខុសត្រូវរបស់ពួកគាត់។ អ្នកគួររៀបចំការសន្ទនាដាច់ដោយឡែករវាងស្ត្រី និងបុរស។ បន្ទាប់មក នាំក្រុមទាំងពីរមកជុំគ្នាវិញ និងចែករំលែកអំពីការពិភាក្សារបស់ពួកគាត់។ ធ្វើដូច្នេះនឹងជួយបង្កើនការយល់ដឹងបានប្រសើរពីទស្សនៈម្ខាងៗ។ សកម្មភាពនៅក្នុងទម្រង់គំរូគ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ។

វិធីមួយទៀតក្រៅពីការប្រើទម្រង់គំរូខាងក្រោម អ្នកអាចបង្កើតជាប្រតិទិនសកម្មភាពប្រចាំថ្ងៃ (២៤ម៉ោង) ឬប្រតិទិនតាមរដូវកាល។ ព័ត៌មានអំពីឧបករណ៍ទាំងនេះមាននៅទីនេះ
http://www.fao.org/3/X5996E/x5996e06.htm#6.2.7.%20Seasonal%20Calendar

## ឧបករណ៍យេនឌ័រនិងការងារ

| សកម្មភាព | ស្ត្រី/កុមារី | បុរស/កុមារា | ទីណា | ពេលណា (ពេល ឬរដូវ) |
|---|---|---|---|---|
| **ការងារពាក់ព័ន្ធនឹងការបន្តពូជ** | | | | |
| • ថែទាំកុមារ/ថែទាំមនុស្សចាស់<br>• ដាំដំណាំបរិភោគនិងចម្អិនម្ហូបសម្រាប់គ្រួសារ<br>• ដងទឹកសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ<br>• រើសអុស<br>• កិច្ចការផ្សេងទៀត (សូមរៀបរាប់) | | | | |
| **ការងារផលិតភាព** | | | | |
| • ការងារនៅក្នុងវិស័យផ្លូវការ<br>• នេសាទ<br>• ដាំដំណាំសម្រាប់លក់<br>• ពាណិជ្ជកម្ម<br>• កិច្ចការផ្សេងទៀត (សូមរៀបរាប់) | | | | |
| **ការងារសហគមន៍** | | | | |
| • ការគ្រប់គ្រងសហគមន៍ (ឧ. ការគ្រប់គ្រងធនធានរួម ដូចជា ទឹក ការថែទាំសុខភាព និងការអប់រំ)<br>• នយោបាយសហគមន៍<br>• កិច្ចការផ្សេងទៀត (សូមរៀបរាប់) | | | | |

**សំណួរបន្ថែម៖**

តើការងាររួមគ្នាមានអ្វីខ្លះ? ____________________

____________________

ហេតុអ្វីបានជាការងារខ្លះសម្រាប់ស្ត្រី និងការងារខ្លះទៀតសម្រាប់បុរស? ____________________

____________________

តើការងាររបស់ស្ត្រីមានតម្លៃស្មើនឹងការងារបុរសដែរទេ (បើមិនស្មើ ហេតុអ្វី)? ____________________

____________________

# ឧបសម្ព័ន្ធទី៦៖
# ជំហានទី៣ - ស្វែងយល់ថា តើនរណាមានសិទ្ធិប្រើប្រាស់ និងចាត់ចែងធនធានក្នុងគ្រួសារនិងសហគមន៍

ជំហាននេះប្រមូលព័ត៌មានអំពីអ្នកមានសិទ្ធិប្រើប្រាស់ និងចាត់ចែងឬគ្រប់គ្រងធនធានក្នុងគ្រួសារនិងសហគមន៍។ ការទទួលបានគឺជាឱកាសក្នុងការប្រើធនធាន ចំណែកឯការចាត់ចែងគឺជាសិទ្ធិអំណាចក្នុងការសម្រេចថាតើធនធានត្រូវប្រើប្រាស់ដូចម្ដេច ហើយនរណាជាអ្នកទទួលបានប្រយោជន៍។ ព័ត៌មានទាំងនេះអនុញ្ញាតឱ្យសហគមន៍និងស្ថាប័នស្វែងយល់កាន់តែច្បាស់ថាតើនរណាអាចនឹងត្រូវរងផលប៉ះពាល់ និងរងប៉ះពាល់របៀបណា ប្រសិនបើធនធានត្រូវបានបាត់បង់ដោយសារការអភិវឌ្ឍទំនប់ (ឧបករណ៍សម្រាប់ជួយវិភាគមាននៅក្នុងឧបសម្ព័ន្ធទី៩)។

គម្រោងទំនប់ច្រើនបង្កផលប៉ះពាល់ដល់ការទទួលបានធនធានផលិតភាពដូចជា ដីធ្លី ព្រៃឈើ ទឹក និងជលផលហេតុដូច្នេះ អ្នកអាចផ្ដោតទៅលើធនធានទាំងនេះ។ ក៏ប៉ុន្តែជាកិច្ចចាប់ផ្ដើម អ្នកគួរសិក្សាអំពីធនធានទាំងអស់ដែលរងហានិភ័យជាមុនសិន បន្ទាប់មកសឹមពិចារណាអំពីការទទួលបាននិងការគ្រប់គ្រងធនធាន។

អ្នកអាចប្រើសំណួរនិងទម្រង់គំរូខាងក្រោម ដើម្បីជាជំនួយក្នុងការចងក្រងឯកសារ និងពិភាក្សាជាមួយស្ត្រីនិងបុរស អំពីធនធានធម្មជាតិដែលមាននៅក្នុងសហគមន៍របស់គាត់ នរណាអាចប្រើប្រាស់បាន នរណាជាអ្នកចាត់ចែង ហើយហេតុអ្វីបានជាដូច្នេះ។ អ្នកគួររៀបចំការសន្ទនាដាច់ដោយឡែករវាងស្ត្រី និងបុរស។ បន្ទាប់មក នាំក្រុមទាំងពីរមកជុំគ្នាវិញ និងចែករំលែកអំពីការពិភាក្សារបស់ពួកគាត់។ ធ្វើដូច្នេះនឹងជួយបង្កើនការយល់ដឹងបានប្រសើរពីទស្សនៈម្ខាងៗ។

ការធ្វើផែនទីសហគមន៍ ការដើរសង្កេតមើលជុំគ្នាតាមផ្លូវ និងសកម្មភាពបែបចូលរួមដទៃទៀត អាចបំពេញបន្ថែមទៅលើការពិភាក្សា និងងាយស្រួលកំណត់រកធនធានបានត្រឹមត្រូវ។ ព័ត៌មានស្ដីពីការធ្វើផែនទីសហគមន៍ (ឬធនធាន) និងឧបករណ៍បែបចូលរួមដទៃទៀត មាននៅទីនេះ
http://www.fao.org/3/X5996E/x5996e06.htm#6.2.7.%20Seasonal%20Calendar

## ១. តើធនធានអ្វីខ្លះដែលសហគមន៍មាន ហើយដែលរងហានិភ័យពីការអភិវឌ្ឍទំនប់?

### ស្វែងយល់ពីធនធានដែលរងផលប៉ះពាល់

| ប្រភេទធនធាន | ផលប៉ះពាល់ដែលអាចកើតមាន ហើយនរណាជាអ្នករងផលប៉ះពាល់ |
|---|---|
| | |
| | |
| | |
| | |
| | |

## ២. បង្កើតទម្រង់ស្ដីអំពីការទទួលបាន និងការគ្រប់គ្រងធនធាន

### ការទទួលបាន និងការគ្រប់គ្រងធនធាន

INTERNATIONAL RIVERS
PEOPLE · WATER · LIFE

| ធនធាន | នរណាអាចទទួល (ឬអាចប្រើ) ធនធាននេះបាន? | | នរណាសម្រេចអំពីការប្រើប្រាស់ធនធាន ហើយនរណាទទួលផលប្រយោជន៍ពីការប្រើប្រាស់? | |
|---|---|---|---|---|
| | ស្ត្រី | បុរស | ស្ត្រី | បុរស |
| ដី | | | | |
| ព្រៃ | | | | |
| ទឹក | | | | |
| ជលផល | | | | |
| ផ្សេងៗ | | | | |

**សំណួរបន្ថែម៖**

តើបុរសនិងស្ត្រីទទួលបានអត្ថប្រយោជន៍អ្វីខ្លះពីធនធានដែលពួកគាត់ទទួលបាននិងគ្រប់គ្រង? ____

________________________________________

ហេតុអ្វីបានជាបុរសទទួលបាននិងគ្រប់គ្រងធនធាន? ____________________

________________________________________

តើអ្វីដែលរារាំងស្ត្រីក្នុងការគ្រប់គ្រងធនធាន? ____________________

________________________________________

# ឧបសម្ព័ន្ធទី៧៖
# ជំហានទី៤ - ស្វែងយល់ពីឧបសគ្គ និងដំណោះស្រាយ ចំពោះការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត

ជំហាននេះស្វែងយល់ពីឧបសគ្គដែលរារាំងការចូលរួមរបស់ស្ត្រីក្នុងការសម្រេចចិត្តនៅក្នុងគ្រួសារ សហគមន៍ និងសង្គមឱ្យបានទូលំទូលាយ។ យើងមានគោលបំណងស្វែងយល់អំពីឧបសគ្គចំពោះការចូលរួមនិងភាពជាអ្នកដឹកនាំរបស់ស្ត្រី នៅក្នុងការពិគ្រោះយោបល់និងការសម្រេចចិត្តជាសាធារណៈជុំវិញគម្រោងទំនប់ និងនៅក្នុងសកម្មភាពយុទ្ធនាការ។ បន្ទាប់មក យើងនឹងបង្កើតយុទ្ធសាស្ត្រដើម្បីជម្នះឧបសគ្គទាំងនេះ។

អ្នកអាចសម្របសម្រួលការពិភាក្សាមួយចំនួនជាមួយស្ត្រីមកពីសហគមន៍រងគ្រោះ ដើម្បីស្វែងយល់អំពីបញ្ហា និងរៀបចំយុទ្ធសាស្ត្រដើម្បីលើកកម្ពស់ការចូលរួមនិងភាពជាអ្នកដឹកនាំរបស់ស្ត្រី។

អ្នកអាចប្រើសំណួរខាងក្រោម ដើម្បីជាជំនួយក្នុងការចងក្រងឯកសារ និងពិភាក្សាជាមួយស្ត្រី។ គួរចែករំលែកលទ្ធផលនៃការពិភាក្សាជាមួយបុរស ពីព្រោះបុរសអាច និងគួរគាំទ្រដល់ការចូលរួមនិងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងយុទ្ធនាការទំនប់និងទន្លេ និងការសម្រេចចិត្តសាធារណៈ។ គួរកត់ត្រាការពិភាក្សាទាំងនេះឱ្យបានត្រឹមត្រូវ។

**ការពិភាក្សា(ដោយមានការសម្របសម្រួល) មានគោលបំណងស្វែងយល់អំពីឧបសគ្គដែលចាំបាច់ត្រូវជម្នះដើម្បីបង្កើនការចូលរួមនិងភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងការសម្រេចចិត្តសាធារណៈនិងក្នុងយុទ្ធនាការទំនប់និងទន្លេ។**

1. តើបញ្ហាអ្វីខ្លះដែលស្ត្រីមានឥទ្ធិពលក្នុងការសម្រេចចិត្ត នៅក្នុងគ្រួសារ និងនៅក្នុងសហគមន៍?
2. តើអ្វីដែលរារាំងឥទ្ធិពលរបស់ស្ត្រីក្នុងការសម្រេចចិត្តនៅផ្ទះនិងនៅក្នុងសហគមន៍?
3. តើស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការសម្រេចចិត្ត និងមានឥទ្ធិពលលើការសម្រេចចិត្តនៅក្នុងសហគមន៍ (ឬជាសាធារណៈ) ដូចបុរសដែរឬទេ? បើទេ, ហេតុអ្វី?
4. តើអ្វីដែលរារាំងស្ត្រីមិនឱ្យចូលរួមក្នុងការសម្រេចចិត្តក្នុងសហគមន៍ (ឬជាសាធារណៈ)?
5. តើអ្វីដែលរារាំងស្ត្រីមិនឱ្យទទួលនូវតួនាទីជាអ្នកដឹកនាំសហគមន៍?
6. តើចាំបាច់ត្រូវការអ្វីដើម្បីឱ្យស្ត្រីអាចចូលរួមនិងមានឥទ្ធិពល ក្នុងការសម្រេចចិត្តក្នុងសហគមន៍ (ឬជាសាធារណៈ) អំពីការអភិវឌ្ឍទំនប់?
7. តើចាំបាច់ត្រូវការអ្វីខ្លះដើម្បីទទួលស្គាល់និងគាំទ្រដល់ភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងយុទ្ធនាការទំនប់និងទន្លេ?

នៅពេលគិតអំពីសំណួរទាំងនេះ ចូរគិតអំពីផលប៉ះពាល់នៃ៖

- ច្បាប់ទម្លាប់សង្គមដែលរឹតត្បិតតួនាទីរបស់ស្ត្រីក្នុងទីសាធារណៈ
- ការងារឬបន្ទុកការងារដែលគ្មានកម្រៃរបស់ស្ត្រី
- ការរំពឹងទុកក្នុងសង្គមដែលគិតថាបុរសគឺជាអ្នកដឹកនាំ
- អំពើហិង្សាលើស្ត្រីក្នុងទីសាធារណៈ
- ការអប់រំ ទំនាក់ទំនង និងធនធានរបស់ស្ត្រីមានកំណត់
- ឧបសគ្គផ្នែកច្បាប់ចំពោះការចូលរួមរបស់ស្ត្រីក្នុងទីសាធារណៈ

# ឧបសម្ព័ន្ធទី៨៖
# ជំហានទី៥ - ស្វែងយល់ពីតម្រូវការយេនឌ័រជាក់ស្តែង និងផលប្រយោជន៍យេនឌ័រជាយុទ្ធសាស្ត្រសម្រាប់ស្ត្រី

ជំហាននេះមានគោលបំណងស្វែងយល់អំពីតម្រូវការយេនឌ័រជាក់ស្តែងនិងផលប្រយោជន៍យេនឌ័រជាយុទ្ធសាស្ត្ររបស់ស្ត្រី និងកត្តារារាំងការសម្រេចបាននូវតម្រូវការនិងផលប្រយោជន៍នេះ។ តម្រូវការយេនឌ័រជាក់ស្តែងគឺជាអ្វីដែលស្ត្រីត្រូវការចាំបាច់ដើម្បីបំពេញកិច្ចការប្រចាំថ្ងៃផ្អែកទៅលើតួនាទីយេនឌ័រ។ ផលប្រយោជន៍យេនឌ័រជាយុទ្ធសាស្ត្រដែលគឺជាកត្តាដែលជួយឱ្យមានការប្រែប្រួលទៅលើអតុល្យភាពនៃឥទ្ធិពល ដើម្បីសម្រេចបានសមភាពរវាងស្ត្រីនិងបុរស (ឧបសម្ព័ន្ធទី១ មាននិយមន័យពិស្តារអំពីពាក្យគន្លឹះនេះ)។

គេមិនអាចបែងចែកឱ្យដាច់រវាងតម្រូវការយេនឌ័រជាក់ស្តែងនិងផលប្រយោជន៍យេនឌ័រជាយុទ្ធសាស្ត្រនោះទេ ពីព្រោះវាអាចមានភាពត្រួតស៊ីគ្នាខ្លះ។ ឧទាហរណ៍ សមត្ថភាពរបស់ស្ត្រីក្នុងការរកប្រាក់ចំណូល អាចផ្គត់ផ្គង់សេដ្ឋកិច្ចគ្រួសាររបស់គាត់ (នេះគឺជាតម្រូវការយេនឌ័រជាក់ស្តែង) ប៉ុន្តែវាក៏ពង្រឹងឥទ្ធិពលរបស់គាត់ក្នុងការសម្រេចចិត្តក្នុងគ្រួសារដែរ (នេះគឺជាផលប្រយោជន៍យេនឌ័រយុទ្ធសាស្ត្រ)។ អ្វីដែលសំខាន់នោះគឺស្ត្រីមានឱកាសកំណត់ពីតម្រូវការនិងផលប្រយោជន៍របស់ពួកគាត់។

ជំហាននេះអាចជួយធានាថា ស្ថាប័នគាំទ្រសហគមន៍រងគ្រោះបានគិតគូរពីតម្រូវការនិងផលប្រយោជន៍របស់ស្ត្រី នៅក្នុងពេលធ្វើផែនការនិងអនុវត្តយុទ្ធនាការ និងការផ្តល់ឱកាសឱ្យស្ត្រីចូលរួមនិងដឹកនាំយុទ្ធនាការ។

អ្នកអាចប្រើសំណួរខាងក្រោម ដើម្បីជាជំនួយក្នុងការចងក្រងឯកសារ និងពិភាក្សាជាមួយស្ត្រី។ គួរចែករំលែកលទ្ធផលនៃការពិភាក្សាជាមួយបុរស ហើយបុរសគួរតស៊ូមតិឱ្យម្ចាស់គម្រោងទំនប់គិតគូរពិចារណាអំពីតម្រូវការនិងផលប្រយោជន៍សម្រាប់ស្ត្រី។

### ការពិភាក្សាដោយមានការសម្របសម្រួល ដើម្បីស្វែងយល់អំពីតម្រូវការនិងផលប្រយោជន៍សម្រាប់ស្ត្រី

| តម្រូវការយេនឌ័រជាក់ស្តែង | ផលប្រយោជន៍យេនឌ័រជាយុទ្ធសាស្ត្រ |
|---|---|
| មានអ្វីខ្លះ? សូមពណ៌នា<br>•<br>•<br>•<br>•<br>•<br>• | មានអ្វីខ្លះ? សូមពណ៌នា<br>•<br>•<br>•<br>•<br>•<br>• |

ខាងក្រោមនេះគឺសំណួរមួយចំនួនដើម្បីស្វែងយល់អំពីតម្រូវការយេនឌ័រជាក់ស្តែងនិងផលប្រយោជន៍យេនឌ័ររបស់ស្ត្រី៖

- តើស្ត្រីត្រូវការអ្វីខ្លះដើម្បីជួយដល់កិច្ចការប្រចាំថ្ងៃរបស់ពួកគាត់?
- តើអ្វីខ្លះដែលរារាំងស្ត្រីមិនឱ្យចាត់ចែងជីវិតរបស់ពួកគាត់?
- តើយើងត្រូវការអ្វីខ្លះដើម្បីគាំទ្រស្ត្រីក្នុងការកែប្រែអតុល្យភាពឥទ្ធិពល?
- តើតម្រូវការយេនឌ័រជាក់ស្តែងរបស់ស្ត្រីមានឥទ្ធិពលយ៉ាងដូចម្តេចទៅលើផលប្រយោជន៍យេនឌ័ររបស់ពួកគាត់?
- តើយើងត្រូវការអ្វីខ្លះដើម្បីគាំទ្រឱ្យមានសមភាពរវាងស្ត្រីនិងបុរស?

# ឧបសម្ព័ន្ធទី៩៖
# ជំហានទី៦ - ស្វែងយល់ពីផលប៉ះពាល់នៃគម្រោងទំនប់ដែលបានស្នើ ដែលអាចកើតមាននៅលើស្ត្រីនិងបុរស

ជំហាននេះស្វែងយល់ថាតើគម្រោងទំនប់មានផលប៉ះពាល់យ៉ាងណាខ្លះទៅលើស្ត្រីនិងបុរស ដើម្បីស្វែងយល់ឱ្យបានពិស្តារអំពីផលប៉ះពាល់ផ្នែកយេនឌ័រ។ គួរប្រើព័ត៌មានទទួលបានពីជំហាននេះដើម្បីការបង្កើតផែនការយុទ្ធនាការយេនឌ័រដោយធានាថាសកម្មភាពយុទ្ធនាការ ផ្តល់អាទិភាពទៅលើការដោះស្រាយផលប៉ះពាល់អវិជ្ជមានរបស់ទំនប់ទៅលើស្ត្រី។

អ្នកអាចរៀបចំការពិភាក្សាដោយមានការសម្របសម្រួលមួយចំនួន ជាមួយស្ត្រីនិងបុរសមកពីសហគមន៍រងគ្រោះដោយសារទំនប់ ដើម្បីស្វែងយល់ពីផលប៉ះពាល់របស់ទំនប់ទៅលើ
១. ការផ្តល់តម្លៃទៅលើទន្លេពីសំណាក់ស្ត្រីនិងបុរស
២. ការងារស្ត្រីនិងការងារបុរស
៣. ធនធានដែលស្ត្រីនិងបុរសប្រើប្រាស់និងគ្រប់គ្រង
៤.ភាពជាអ្នកដឹកនាំនិងការចូលរួមរបស់ស្ត្រីក្នុងការសម្រេចចិត្ត
៥. តម្រូវការនិងផលប្រយោជន៍សម្រាប់ស្ត្រី។

ចាំបាច់ត្រូវពិចារណាលើព័ត៌មានដែលប្រមូលបានក្នុងជំហានទាំងបួនមុន។ សំណួរនៅក្នុងទម្រង់គំរូគឺសម្រាប់ជាអនុសាសន៍ប៉ុណ្ណោះ។ សំណួរទាំងនេះគឺសម្រាប់ឆ្លុះបញ្ចាំងអំពីផលប៉ះពាល់របស់ទំនប់ទៅលើស្ត្រីនិងបុរស។

អ្នកអាចរៀបចំជាកិច្ចពិភាក្សាដាច់ដោយឡែករវាងស្ត្រី និងបុរស។ បន្ទាប់មក នាំក្រុមទាំងពីរមកជុំគ្នាវិញ និងចែករំលែកអំពីការពិភាក្សារបស់ពួកគាត់។ អ្នកអាចប្រើព័ត៌មានដែលប្រមូលបានតាមរយៈលំហាត់ផែនទី នៅក្នុងឧបសម្ព័ន្ធទី៤។ គួរកត់ត្រាការពិភាក្សាទាំងនេះឱ្យបានត្រឹមត្រូវ។

## ចូរសម្របសម្រួលការពិភាក្សាដើម្បីស្វែងយល់អំពីផលប៉ះពាល់នៅក្នុងចំនុចទាំង៥ ដូចខាងក្រោម៖

ការអភិវឌ្ឍទំនប់នឹងនាំឱ្យមានផលប៉ះពាល់ដូចជា ការផ្លាស់ប្តូរទីលំនៅដោយបង្ខំដោយសារដីធ្លីត្រូវលិចលង់ដោយសារអាងស្តុកទឹកទំនប់ និងបម្រែបម្រួលប្រព័ន្ធវារីសាស្រ្តទន្លេ។ តើផលប៉ះពាល់ទាំងនេះមានឥទ្ធិពលអ្វីខ្លះទៅលើ៖

### ផលប៉ះពាល់ផ្នែកយេនឌ័រ

INTERNATIONAL RIVERS
PEOPLE · WATER · LIFE

#### គុណប្រយោជន៍របស់ទន្លេដែលស្រ្តីនិងបុរសទទួលបាន

- តើអ្វីខ្លះដែលមានសំខាន់ចំពោះស្រ្តី ហើយនឹងត្រូវបាត់បង់ដោយសារទំនប់?
- តើអ្វីខ្លះដែលមានសំខាន់ចំពោះបុរស ហើយនឹងត្រូវបាត់បង់ដោយសារទំនប់?

#### តម្រូវការយេនឌ័រជាក់ស្តែងនិងផលប្រយោជន៍យេនឌ័រជាយុទ្ធសាស្រ្តសម្រាប់ស្រ្តី

- តើគម្រោងទំនប់អាចបង្កឱ្យខូចខាតតម្រូវការយេនឌ័រជាក់ស្តែងរបស់ស្រ្តីយ៉ាងដូចម្តេចខ្លះ?
- តើគម្រោងទំនប់ (រួមទាំងការពិគ្រោះយោបល់សហគមន៍) អាចបង្កឱ្យខូចខាតដល់ផលប្រយោជន៍យេនឌ័ររបស់ស្រ្តីយ៉ាងដូចម្តេចខ្លះ?
- តើគម្រោងទំនប់នេះអាចជួយស្រ្តីឱ្យសម្រេចបាននូវតម្រូវការយេនឌ័រនិងផលប្រយោជន៍យេនឌ័រទេ? បើបាន តើនឹងបានដោយរបៀបណា?

#### ការទទួលបាននិងការគ្រប់គ្រងធនធាន

- តើធនធានអ្វីខ្លះដែលស្រ្តីកំពុងទទួលបាននិងគ្រប់គ្រងដែលនឹងត្រូវបំផ្លាញដោយសារទំនប់នេះ?
- តើបញ្ហានេះនឹងមានផលប៉ះពាល់អ្វីខ្លះទៅលើស្រ្តី?
- តើធនធានអ្វីខ្លះដែលបុរសកំពុងទទួលបាននិងគ្រប់គ្រង ដែលនឹងត្រូវបំផ្លាញដោយទំនប់នេះ?
- តើបញ្ហានេះនឹងមានផលប៉ះពាល់អ្វីខ្លះទៅលើបុរស?
- តើស្រ្តីនឹងទទួលបានសំណងចំពោះការបាត់បង់ធនធានរបស់គាត់ ដូចបុរសដែរឬទេ?
- តើវានឹងប៉ះពាល់យ៉ាងដូចម្តេចទៅលើទំនាក់ទំនងនៃឥទ្ធិពលរវាងស្រ្តីនិងបុរស?

#### ការបែងចែកពលកម្មយេនឌ័រ

- តើការងាររបស់នរណានឹងរងផលប៉ះពាល់ ហើយប៉ះពាល់ដូចម្តេច? (រាប់ទាំងការងារពាក់ព័ន្ធនឹងការបន្តពូជ ការងារផលិតភាព និងការងារសហគមន៍)?
- តើបន្ទុកការងាររបស់ស្រ្តីនឹងកើនឡើងឬទេ?
- សម្រាប់ស្រ្តី តើការងារមើលថៃ (ដែលគ្មានប្រាក់កម្រៃ) នឹងកើនឡើងដែរឬទេ?
- តើបន្ទុកការងាររបស់បុរសនឹងកើនឡើងឬទេ?
- តើចំណូលរបស់ស្រ្តីនិងបុរសនឹងមានការផ្លាស់ប្តូរឬទេ? បើប្តូរ តើនឹងប្តូររបៀបណា?
- តើបម្លាស់ប្តូរការងាររបស់ស្រ្តីនិងបុរសអាចមានឥទ្ធិពលលើទំនាក់ទំនងឥទ្ធិពលរវាងស្រ្តីនិងបុរសយ៉ាងដូចម្តេច?

#### ភាពជាអ្នកដឹកនាំនិងការចូលរួមរបស់ស្រ្តីក្នុងការសម្រេចចិត្ត

- តើដំណើរការពិគ្រោះយោបល់សហគមន៍នឹងលើកទឹកចិត្ត ឬក៏ ធ្វើឱ្យខូចបង់ដល់ការចូលរួមនិងភាពជាអ្នកដឹកនាំរបស់ស្រ្តី?
- តើសំឡេងនិងមតិរបស់នរណានឹងត្រូវបានគេទទួលយកខ្លាំងជាងគេ?
- តើសហគមន៍នឹងរងផលប៉ះពាល់អ្វីខ្លះ ប្រសិនបើរដ្ឋាភិបាលនិងអ្នកអភិវឌ្ឍទំនប់មិនស្តាប់សំឡេងនិងយោបល់របស់ស្រ្តី?

# ឧបសម្ព័ន្ធទី១០៖ បញ្ជីផ្ទៀងផ្ទាត់ផែនការយុទ្ធនាការដែលឆ្លើយតបទៅនឹងយេនឌ័រ

បញ្ជីផ្ទៀងផ្ទាត់នេះគឺជាជំនួយដល់ស្ថាប័ន ដើម្បីធានាថាយុទ្ធនាការទំនប់និងទន្លេរបស់ខ្លួនឆ្លើយតបនឹងយេនឌ័រ។ បញ្ជីផ្ទៀងផ្ទាត់នេះអាចប្រើសម្រាប់វាយតម្លៃលទ្ធភាពឆ្លើយតបនឹងយេនឌ័រ និងដើម្បីកែលម្អផែនការយុទ្ធនាការដោយផ្តោតអារម្មណ៍ទៅលើបញ្ហាយេនឌ័រ។ ម៉្យាងវិញទៀត បញ្ជីផ្ទៀងផ្ទាត់នេះអាចត្រូវបានកែប្រែនិងប្រើប្រាស់ជាឧបករណ៍រៀបចំផែនការក៏បាន។

គួរពិនិត្យបញ្ជីផ្ទៀងផ្ទាត់នេះជាមួយអង្គការដៃគូនានា និងស្ត្រីនិងបុរសមកពីសហគមន៍ដែលអ្នកធ្វើការជាមួយ។ ធ្វើបែបនេះនឹងនាំឱ្យមានការយល់ដឹងរួមគ្នាអំពីផែនការ ហើយនឹងធានាថាយុទ្ធនាការនេះបានគិតគូរពីបទពិសោធន៍និងទស្សនៈរបស់ស្ត្រីនិងបុរស និងធ្វើការដើម្បីផលប្រយោជន៍របស់ស្ត្រីនិងបុរស។

## ជំហានបន្ទាប់៖

- ពិនិត្យឡើងវិញនូវផែនការយុទ្ធនាការរបស់អ្នក (និងផែនការប្រាស្រ័យទាក់ទង) ដោយផ្អែកលើការវាយតម្លៃនេះ។
- ធានាថាមានថវិកាគ្រប់គ្រាន់ដើម្បីគាំទ្រយេនឌ័រនៅក្នុងយុទ្ធនាការ (រួមទាំងការពង្រឹងសមត្ថភាពយេនឌ័រ សកម្មភាពសម្រាប់តែស្ត្រី ជំនួយលើការធ្វើដំណើរ ឬការជួយមើលថែកុមារ ដើម្បីឱ្យស្ត្រីមានឱកាសចូលរួម)។
- បង្កើតសូចនាករនិងក្របខ័ណ្ឌត្រួតពិនិត្យ ដើម្បីឱ្យបុគ្គលិកអាចវាយតម្លៃភាពជោគជ័យនៃយុទ្ធនាការ ក្នុងការបំពេញតម្រូវការនិងផលប្រយោជន៍របស់ស្ត្រីនិងបុរស។
- តាមដានការអនុវត្តផែនការ ដោយប្រើសូចនាករយេនឌ័រនិងក្របខ័ណ្ឌត្រួតពិនិត្យ។
- វាយតម្លៃថា តើយុទ្ធនាការនេះបន្លឺសំឡេងរបស់ស្ត្រីមកពីសហគមន៍រងគ្រោះ គាំទ្រដល់ការចូលរួមនិងភាពជាអ្នកដឹកនាំរបស់ស្ត្រី និងធានានូវចំនួនស្ត្រីនិងបុរសស្មើគ្នានៅក្នុងការប្រជុំជាមួយម្ចាស់គម្រោង ការប្រជុំបណ្តាញសង្គមស៊ីវិល និងការកសាងសមត្ថភាព ឬទេ។

## បញ្ជីផ្ទៀងផ្ទាត់ផែនការយុទ្ធនាការដែលឆ្លើយតបទៅនឹងយេនឌ័រ

| សំណួរគន្លឹះ | ចម្លើយ រួមទាំងសេចក្តីពន្យល់អំពីការកែប្រែផែនការដើម្បីឱ្យឆ្លើយតបទៅនឹងយេនឌ័រ |
|---|---|
| តើយុទ្ធនាការមានវត្ថុបំណងនិងគោលដៅអ្វីខ្លះ?<br>. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .<br>. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .<br>• តើវត្ថុបំណងទាំងនេះឆ្លើយតបនឹងតម្រូវការនិងផលប្រយោជន៍ទាំងស្ត្រីនិងបុរសយ៉ាងដូចម្តេច?<br>• តើការវិភាគយេនឌ័របានផ្តល់ព័ត៌មានអ្វីខ្លះអំពីវត្ថុបំណងនិងគោលដៅនៃយុទ្ធនាការ?<br>• តើស្ត្រីនិងបុរសមកពីសហគមន៍រងគ្រោះបានចូលរួមអ្វីខ្លះក្នុងការរៀបចំគោលបំណង យុទ្ធសាស្ត្រ សកម្មភាពយុទ្ធនាការ?<br>• តើស្ត្រីមានឥទ្ធិពលអ្វីខ្លះចំពោះការរៀបចំគោលបំណង យុទ្ធសាស្ត្រ និងសកម្មភាព? | |
| តើយុទ្ធនាការលើកកម្ពស់ឬព្យាយាមការពារយ៉ាងដូចម្តេច ទៅលើ៖<br>• គុណតម្លៃដែលស្ត្រីផ្តល់ឱ្យទន្លេ?<br>• គុណតម្លៃដែលបុរសផ្តល់ឱ្យទន្លេ? | |
| តើយុទ្ធនាការព្យាយាមការពារយ៉ាងដូចម្តេចទៅលើ៖<br>• ការទទួលបាននិងការគ្រប់គ្រងធនធានរបស់ស្ត្រី?<br>• ការទទួលបាននិងការគ្រប់គ្រងធនធានរបស់បុរស? | |
| តើយុទ្ធនាការធ្វើអ្វីខ្លះដើម្បីការពារកុំឱ្យ៖<br>• បន្ទុកការងាររបស់ស្ត្រីកើនឡើង (រាប់បញ្ចូលទាំងការងារថែទាំគ្មានកម្រៃ) និងប្រាក់ចំណូលថយចុះ?<br>• បន្ទុកការងាររបស់បុរសកើនឡើង និងប្រាក់ចំណូលថយចុះ? | |
| • តើយុទ្ធនាការមានបំណងជម្នះដោយរបៀបណាលើឧបសគ្គដែលរារាំងការចូលរួមនិងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងយុទ្ធនាការនិងការសម្រេចចិត្តសាធារណៈ? | |
| តើយុទ្ធនាការលើកកម្ពស់ឬព្យាយាមការពារ៖<br>• តម្រូវការយេនឌ័រជាក់ស្តែងនិងផលប្រយោជន៍យេនឌ័រជាយុទ្ធសាស្ត្ររបស់ស្ត្រី ដោយរបៀបណា? | |
| តើយុទ្ធនាការនេះអាចមានលទ្ធភាពបង្កផលប៉ះពាល់ជាអវិជ្ជមានចំពោះស្ត្រីឬបុរសដែរឬទេ? តើមានវិធីក្នុងការគ្រប់គ្រងផលប៉ះពាល់ឬហានិភ័យទាំងនោះ ដោយរបៀបណា? | |

# ឯកសារយោង

*ការវាយតម្លៃផលប៉ះពាល់លើសិទ្ធិមនុស្សនៅតាមសហគមន៍៖ សៀវភៅណែនាំការបណ្តុះបណ្តាល - ឧបករណ៍ជំនួយដែលត្រឹមត្រូវ*, ឆ្នាំ២០០៩, អុកស្វាម និងសហព័ន្ធអន្តរជាតិសម្រាប់សិទ្ធិមនុស្ស
https://www.oxfamamerica.org/static/media/files/COBHRA_Training_Manual_-_English.pdf

*ទំនប់និងការអភិវឌ្ឍ៖ ក្របខ័ណ្ឌថ្មីសម្រាប់ការសម្រេចចិត្ត*, របាយការណ៍របស់គណៈកម្មការពិភពលោកស្តីពីទំនប់វារីអគ្គិសនី, ឆ្នាំ២០០០
https://www.internationalrivers.org/sites/default/files/attached-files/world_commission_on_dams_final_report.pdf

*សៀវភៅណែនាំរបស់អ្នកសម្របសម្រួល៖ កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្តីពីការបញ្ជ្រាបយេនឌ័រ*, ឆ្នាំ២០០២, អង្គការសហប្រជាជាតិ
https://www.un.org/womenwatch/osagi/pdf/CompetenceDevelopmentFacilitatorsManual.pdf

*សទ្ទានុក្រមសមភាពយេនឌ័រ*, អង្គការសហប្រជាជាតិដើម្បីស្ត្រី
https://trainingcentre.unwomen.org/mod/glossary/view.php?id=36

*កញ្ចប់សម្ភារៈសម្រាប់យេនឌ័រ*, ឆ្នាំ២០១៨, មូលនិធិភាពជាដៃគូប្រព័ន្ធអេកូឡូស៊ី
https://www.cepf.net/sites/default/files/cepf-gender-toolkit-2018-en.pdf

ហីល គ្រីស្ទីណា ជាមួយ គ្រីស មិដដិន និងនីណា ខូលីន, *សៀវភៅមគ្គុទេសក៍ស្តីអំពីការវាយតម្លៃផលប៉ះពាល់យេនឌ័រសម្រាប់ឧស្សាហកម្មរ៉ែ*, ឆ្នាំ២០១៧, អង្គការអុកស្វាមអូស្ត្រាលី
https://www.oxfam.org.au/wp-content/uploads/2017/04/2017-PA-001-Gender-impact-assessments-in-mining-report_FA_WEB.pdf

ហីល គ្រីស្ទីណា ជាមួយ ផាន ធី ងុក ធុយ, ហ្សាកឹលីន ស្តូរ៉េ និងស៊ីឡាវ៉ាន់ វង្សផូស៊ី, ឆ្នាំ២០១៧, *មេរៀនបទពិសោធន៍ពីការវាយតម្លៃផលប៉ះពាល់យេនឌ័រនៃគម្រោងវារីអគ្គិសនីនៅប្រទេសឡាវនិងវៀតណាម*, យេនឌ័រនិងការអភិវឌ្ឍ, ទំព័រ ២៥:៣, ៤៥៥-៤៧០, ឆ្នាំ២០១៧, អង្គការអុកស្វាមជីប៊ីរូលេច។
https://policy-practice.oxfam.org.uk/publications/lessons-learnt-from-gender-impact-assessments-of-hydropower-projects-in-laos-an-620369

*សៀវភៅមគ្គុទេសក៍របស់អុកស្វាមអំពីឥទ្ធិពលស្ត្រី*, ឆ្នាំ២០១៩, អង្គការអុកស្វាមអន្តរជាតិ
https://www.oxfam.org/en/research/oxfams-guide-feminist-influencing

រេជឌី ទ្រូសា ជាមួយ រ៉ូជូ សានយ៉ានហ្គា, តាហ្វាតវ៉ា ម៉ាហូបាបា និងអានហ្គី អាសានហ្ស៊ី, *ស្ត្រី អ្នកថែរក្សាទន្លេទប់ទល់នឹងទំនប់វារីអគ្គិសនីធំៗ៖ មគ្គទេសក៍សម្រាប់សកម្មជនស្ត្រីនៅទ្វីបអាហ្វ្រិក*, ឆ្នាំ២០១៩, អង្គការទន្លេអន្តរជាតិ និងអង្គការវ៉ូមីន (WoMin)
https://womin.org.za/images/activist-guides/FightingBigDamsfinal.pdf

ស្កូឌ័រ ថាយឺ និងខូលសាន់ អេលីសាបែត *"សុខុមាលភាព និងការអភិវឌ្ឍ៖ ក្របខ័ណ្ឌគំនិតសម្រាប់ការវិភាគអំពីប្រជាជនដែលត្រូវផ្លាស់ប្តូរទីលំនៅ" ចំណាកស្រុកនិងការតាំងទីលំនៅថ្មីដោយបង្ខំ៖ បញ្ហានិងការឆ្លើយតបរបស់ប្រជាជនដែលត្រូវផ្លាស់ទីលំនៅ។* ហាន់សេន អេ និងអូលីវើ ស្មីត អេ (eds) រោងពុម្ពវេសវីយូ, ឆ្នាំ១៩៨២, បូលឌឺ ខូឡូរ៉ាដូ

ស៊ីម៉ូន ម៉ៃឃឹល, *តុល្យភាពជញ្ជីង៖ ការវាយតម្លៃផលប៉ះពាល់យេនឌ័រនៅក្នុងការអភិវឌ្ឍវារីអគ្គិសនី*, ឆ្នាំ២០១៣, អង្គការអុកស្វាមអូស្ត្រាលី
https://resources.oxfam.org.au/pages/view.php?ref=1210&search=gender+hydropower&order_by=relevance&sort=DESC&offset=0&archive=0&k=&curpos=5

*សៀវភៅណែនាំរបស់អុកស្វាមអំពីការបណ្តុះបណ្តាលយេនឌ័រ*, ឆ្នាំ១៩៩៤, អង្គការអុកស្វាម
https://policy-practice.oxfam.org.uk/publications/the-oxfam-gender-training-manual-141359



ទន្លេគុណេនេនេ | រូបថតដោយ
អង្គការជីវិតផែនដី អាហ្វ្រិក ណាមីបា

**ការិយាល័យកណ្តាល អង្គការទន្លេអន្តរជាតិ**
1330 Broadway, ជាន់ទី៣
អូកលែន (Oakland), CA 94612, សហរដ្ឋអាមេរិក
ទូរសព្ទ៖ +1 510 848 1155

www.internationalrivers.org

**ការិយាល័យអាហ្វ្រិក អង្គការទន្លេអន្តរជាតិ**
អាគារការិយាល័យ F10, Pro-Equity Court
លេខ 1250 ផ្លូវព្រីតូរីស (Pretorius)
ហេតហ្វៀល (Hatfield), 0083
ព្រីតូរៀ (Pretoria) អាហ្វ្រិកខាងត្បូង
ទូរសព្ទ៖ +27 12 430 2029

INTERNATIONAL RIVERS
PEOPLE · WATER · LIFE